Funded by:

Australian AID

One Vision, One Identity, One Community

www.asean.org

AANZFTA

# Primer on Rules of Origin

ASEAN – AUSTRALIA – NEW ZEALAND
## Free Trade Area

CD-ROM Included

# ឯកសារដំបូងស្តីពី
# វធានដើមកំណើត

## តំបន់ពាណិជ្ជកម្មសេរី
## អាស៊ាន-អូស្ត្រាលី-ណូវែ៉លហ្សេឡង់

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧។ រដ្ឋសមាជិកនៃសមាគមមាន ប្រ៊ុយណេដារ៉ូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ភីឌីអ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ លេខាធិការដ្ឋានអាស៊ានមាន មូលដ្ឋាននៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

**សម្រាប់តម្រូវការផ្សេងៗ សូមទាក់ទង:**
លេខាធិការដ្ឋានអាស៊ាន
ផ្នែកផ្សព្វផ្សាយសាធារណៈ និងសង្គមស៊ីវិល
និង/ឬ ទំនាក់ទំនងសេដ្ឋកិច្ចខាងក្រៅ
អគារ ៧0A ផ្លូវស៊ីស៊ីងហ្គាម៉ាន់ហ្គារ៉ាចា
ហ្សាកាតា ១២១១០
ឥណ្ឌូនេស៊ី
ទូរស័ព្ទ : (62 21) 724-3372, 726-2991
ទូរសា : (62 21) 739-8234, 724-3504
អ៊ីម៉ែល : public.div@asean.org

ព័ត៌មានទូទៅស្តីពីអាស៊ានមាននៅលើគេហទំព័រអាស៊ាន
www.asean.org

កាតាឡុកក្នុងការបោះពុម្ពឯកសារ
ឯកសារដំបូងស្តីពីវិធានដើមកំណើត-តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់
ហ្សាកាតា: លេខាធិការដ្ឋានអាស៊ាន ខែឧសភា ឆ្នាំ២០១០

382.71
១. វិញ្ញាបនបត្រដើមកំណើត-ការការពារនិយម-ពាណិជ្ជកម្មសេរី
២. អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

ISBN 978-602-8411-26-4
បោះពុម្ពលើកទី១ : ខែតុលា ឆ្នាំ២០០៩
ព្រីនឡើងវិញលើកទី១: ឧសភា ២០១០

អត្ថបទនៅក្នុងការផ្សព្វផ្សាយនេះបានដកស្រង់ដោយសេរី និងបានព្រីនឡើងវិញទៅតាមការជូនដំណឹងយ៉ាងត្រឹមត្រូវ។

កម្មសិទ្ធិរបស់លេខាធិការដ្ឋានអាស៊ាន ២០១០
រក្សាសិទ្ធិគ្រប់បែបយ៉ាង

**ការបដិសេធ**

ការបោះពុម្ពនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងសម្រួលដល់ការយល់ដឹងពីការព្រមព្រៀង បង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA)។ ក្នុងលក្ខណៈជាសៀវភៅណែនាំ វាមិនមែនជាផ្នែកមួយនៃកិច្ចព្រមព្រៀង និងមិនបានផ្តល់ ឬក្នុងគោលបំណងផ្តល់ការបកស្រាយស្របច្បាប់ណាមួយនៃកិច្ចព្រមព្រៀងឡើយ។

ជាជំនួយក្នុងការស្វែងយល់ឧទាហរណ៍ខ្លះត្រូវបានបញ្ចូល ប៉ុន្តែគ្រាន់តែជាការបញ្ជាក់សើរៗ និងមិនបានផ្តល់ការវិនិច្ឆ័យ និងមិនចាត់ទុកជាការផ្តល់យោបល់ពាណិជ្ជកម្មឡើយ។ គំនិត និងសេចក្តីសន្និដ្ឋាន អាចត្រូវបានបញ្ជាក់ ប៉ុន្តែទាំងនេះមិនត្រូវបានចាត់ទុកថាជាការណែនាំស្របច្បាប់ ឬពាណិជ្ជកម្មឡើយ។

ការប្រើប្រាស់ផែនទី ក្នុងការបោះពុម្ពនេះត្រូវបានធ្វើឡើងដោយគូសបញ្ជាក់សើរៗ អំពីប្រទេសចូលរួមទៅនឹងកិច្ចព្រមព្រៀង។ វាមិនមែនជាការអះអាងក្នុងការផ្តល់ការវិនិច្ឆ័យស្របច្បាប់/បកស្រាយអំពីព្រំប្រទល់ភូមិសាស្ត្រ។

លេខាធិការដ្ឋានអាស៊ានបានយកចិត្តទុកដាក់ក្នុងការរៀបចំការបោះពុម្ពនេះ។ យ៉ាងណាក៏ដោយ លេខាធិការដ្ឋានអាស៊ានមិនទទួលខុសត្រូវក្នុងការលុប ឬភាពមិនច្បាស់លាស់នៅក្នុងអត្ថបទបោះពុម្ព។ ទាំងលេខាធិការដ្ឋានអាស៊ាន និង AusAID មិនមានលទ្ធភាពទទួលយកការជំទាស់ បាត់បង់ ឬចំណាយដែលអាចកើតឡើង ឬកើតឡើងពីការប្រើព័ត៌មាននៅក្នុងការបោះពុម្ពនេះ។ ការជឿជាក់លើព័ត៌មាន គឺជាហានិភ័យ/ការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់។

ការបោះពុម្ពនេះមិនបានឆ្លុះបញ្ចាំងពីគំនិតរបស់បណ្តាភាគីនៃកិច្ចព្រមព្រៀង លេខាធិការដ្ឋានអាស៊ាន ឬAusAID ឡើយ។

## អារម្ភកថា

កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ( AANZFTA) គឺជាបង្គោលចាំបាច់សម្រាប់សេដ្ឋកិច្ចនៃរដ្ឋសមាជិកទាំង ១០ របស់អាស៊ាន អូស្ត្រាលី និងណូវែលហ្សេឡង់។ កិច្ចព្រមព្រៀងនេះ ជាលទ្ធផលកំពូលនៃការពិគ្រោះ និងចរចាដែលបានចាប់ផ្តើមពីឆ្នាំ ២០០៥។ កិច្ចព្រមព្រៀងបានចុះហត្ថលេខា នៅខែកុម្ភៈ ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០។

កិច្ចព្រមព្រៀង តាមរយៈជំពូកពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ គឺជាការសង្ឃឹមក្នុងការបើកឱកាសពាណិជ្ជកម្មសម្រាប់ពាណិជ្ជករ និងអ្នកនាំចេញ ដែលអាចហុចផលប្រយោជន៍ទាំងប្រតិបត្តិករសេដ្ឋកិច្ច និងអ្នកប្រើប្រាស់។ តាមរយៈនេះ ការយល់ដឹងពីដើមកំណើតទំនិញ អាចឲ្យអ្នកផលិតពាណិជ្ជករ និងអ្នកនាំចេញ ប្រាកដថាអាចទទួលបានផលប្រយោជន៍យ៉ាងច្រើនពីប្រព្រឹត្តិកម្មពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀង។

ឯកសារដំបូងមានបំណងក្នុងការផ្តល់ឲ្យដល់ប្រតិបត្តិករសេដ្ឋកិច្ចនៅក្នុងអាស៊ាន និងពន្យល់ពួកគេពីវិធានដើមកំណើតដែលត្រូវការ សម្រាប់បំពេញលក្ខខណ្ឌទំនិញរបស់ពួកគេ ដើម្បីទទួលបានប្រព្រឹត្តិកម្មពន្ធអនុគ្រោះក្រោម AANZFTA។ ឯកសារនេះមានរួមបញ្ចូលផងដែរពីនីតិវិធីដែលប្រើប្រាស់ដោយអាជ្ញាធរក្នុងការកំណត់ពីការប្រតិបត្តិតាមវិធានដើមកំណើត។

យើងសង្ឃឹមថាឯកសារនេះនឹងណែនាំពាណិជ្ជករ និងអ្នកនាំចេញ ក្នុងការយល់ដឹងពីសមាសភាពនៃវិធានដើមកំណើត AANZFTA និងលើកទឹកចិត្តពួកគេឲ្យប្រើប្រាស់ និងទាញយកផលប្រយោជន៍ពី AANZFTA។

ដោយអាស៊ានចាប់ផ្តើមអនុវត្ត AANZFTA យើងលើកទឹកចិត្តពាណិជ្ជករ និងអ្នកនាំចេញ ដើម្បីយកឱកាសនៃគុណសម្បត្តិពេញលេញដែលបានផ្តល់ក្រោម AANZFTA និងនាំមកនូវសេដ្ឋកិច្ចរុងរឿងសម្រាប់តំបន់។

**បណ្ឌិត សុរិន ពិនសុវ៉ាន់**
អគ្គលេខាធិការអាស៊ាន

## សេចក្ដីថ្លែងអំណរគុណ

យើងសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួម និងគាំទ្រ ក្នុងការស្ថាបនាសៀវភៅណែនាំនេះ បើគ្មានការចូលរួម និងគាំទ្រទេ សៀវភៅនេះមិនអាច...

... ចំពោះ អេនគ្រូ ស្ដូលី ក្នុងការចែករំលែកចំណេះដឹង និងជំនាញ ក្នុងការបង្កើតសម្រាប់ការបោះពុម្ព សៀវភៅនេះ

... ចំពោះអ្នកជំនាញពីលេខាធិការដ្ឋានអាស៊ាន ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី សេវាគយអូស្ត្រាលី ក្រសួងការបរទេស និងពាណិជ្ជកម្មណូវែលហ្សេឡង់ សម្រាប់ពេលវេលាមានតម្លៃ ក្នុងការពិនិត្យមុនការបោះពុម្ពនេះ

... ចំពោះក្រុមការងារលេខាធិការដ្ឋានអាស៊ាន ដែលបានសម្របសម្រួលក្នុងការបង្កើតសៀវភៅណែនាំនេះ សម្រាប់រួមចំណែកក្នុងការអនុវត្តឲ្យរលូនគម្រោងនេះ

... ចំពោះបុគ្គលិកដទៃទៀតរបស់លេខាធិការដ្ឋានអាស៊ាន ក្នុងជំនួយបច្ចេកទេស

... ចំពោះ AusAID ក្នុងការគាំទ្រគំនិតផ្ដួចផ្ដើមរបស់យើង និង

... ចុងក្រោយ ចំពោះមនុស្សទាំងអស់ដែលបានចូលរួមក្នុងការចរចា AANZFTA សម្រាប់ការខិតខំប្រឹងប្រែងពុះពារឥតឈប់ឈរក្នុងការបញ្ចប់កិច្ចព្រមព្រៀង។

**លេខាធិការដ្ឋានអាស៊ាន**

## មាតិកា

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

ផ្នែក ១ - សេចក្តីផ្តើម

ហេតុអ្វីត្រូវមានវិធានដើមកំណើតនៅក្នុងពាណិជ្ជកម្មសេរី?

ទស្សនៈគន្លឹះនៅក្នុងវិធានដើមកំណើតពាណិជ្ជកម្មសេរី

ការអះអាងការនាំចេញរបស់អ្នក ស្របតាមវិធានដើមកំណើត

ផ្នែក ២ - សេចក្តីផ្តើមនៃវិធានដើមកំណើត AANZFTA

ភាពទន់ភ្លន់សម្រាប់អ្នកនាំចេញ

ការបូកផ្សំតំបន់: ការជំរុញសមាហរណកម្មឲ្យកាន់តែច្រើនឡើង

ទំនិញដើមកំណើតកកើតទាំងស្រុងនៅក្នុង AANZFTA

វិធានដើមកំណើតដែលបញ្ចូលតេស្តនៃការប្រែប្រួលដុំកំភួន

ផ្នែក ៣ - តើបទប្បញ្ញត្តិវិធានដើមកំណើតនៅក្នុង AANZFTA នៅទីណា?

ផ្នែក ៤ - តើទីណាដែលអាចរកឃើញវិធានដើមកំណើតសម្រាប់ទំនិញជាក់លាក់?

ផ្នែក ៥ - ការគណនាសមាសភាគតម្លៃតំបន់ (RVC)

រូមមន្តដោយផ្ទាល់

រូបមន្តដោយប្រយោល/Build-down

ការកែច្នៃ និងការប្រតិបត្តិតិចតួច

ផ្នែក ៦ - ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ (CTC)

ភាពទន់ភ្លន់នៃ CTC ក្រោម AANZFTA: បទប្បញ្ញត្តិដឺមីនីមីស

ប្រព័ត្តិកម្មសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ផ្សេងៗ

ផ្នែក ៧ - វិធានដើមកំណើតក្រៅពី RVC និង CTC

វិធានប្រតិកម្មគីមី

ឧទាហរណ៍វិធានពិសេសដទៃទៀត

ផ្នែក ៨ - ការរំពឹងដទៃទៀតដើម្បីបំពេញតម្រូវការវិធានដើមកំណើតAANZFTA

ការបញ្ជូនទំនិញដោយត្រង់

វត្ថុធាតុដូច និងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន

វត្ថុធាតុផ្ទាល់
ផ្នែក ៩ - នីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រ AANZFTA
នីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រ (OCP)៖ មួយជំហានម្តងៗ
ទម្រង់វិញ្ញាបនបត្រ
វិញ្ញាបនបត្រប្រតិសកម្ម
ការផ្ទៀងផ្ទាត់ដើមកំណើតក្រោម AANZFTA
ការរក្សាទុកឯកសារ
ការទទួលស្គាល់វិញ្ញាបនបត្រដើមកំណើតដោយអាជ្ញាធរនាំចូល
ការបូកផ្សំ និងវិញ្ញាបនបត្រដើមកំណើត
ផ្នែក ១០ - ការប្រៀបធៀបវិធានដើមកំណើត AANZFTA និង FTA ដទៃទៀត
ភាពស្រដៀងគ្នានៃគោលការណ៍
ភាពខុសគ្នានៃគោលការណ៍
ឧបសម្ព័ន្ធរង ១ - នីតិវិធីផ្ទៀងផ្ទាត់ក្រោមវិធានដើមកំណើត AANZFTA
ការផ្តួចផ្តើមនីតិវិធីផ្ទៀងផ្ទាត់
ការឆ្លើយតបទៅនឹងផ្ទៀងផ្ទាត់
លទ្ធផលនៃការផ្ទៀងផ្ទាត់
ឧបសម្ព័ន្ធរង ២- លំហាត់អនុវត្តវិធានដើមកំណើត
ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ (CTC)
សមាសភាគតម្លៃតំបន់ (RVC)
ចម្លើយទៅនឹងលំហាត់
ឧបសម្ព័ន្ធរង ៣- ការប្រៀបធៀបគោលការណ៍វិធានដើមកំណើត និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម
អាស៊ានជ្រើសយក
ឧបសម្ព័ន្ធរង ៤- ទម្រង់គំរូសម្រាប់វិញ្ញាបនបត្រដើមកំណើតAANZFTA
វិញ្ញាបនបត្រដើមកំណើត AANZFTA
កំណត់សម្គាល់វិញ្ញាបនបត្រដើមកំណើត
ការណែនាំ ការបំពេញព័ត៌មានអំពីលក្ខណៈវិនិច្ឆ័យនៃការផ្តល់ដើមកំណើត
លើវិញ្ញាបនត្រ AANZFTA
ទម្រង់ប្រកាសរបស់អ្នកនាំចេញ

## បញ្ជីប្រអប់

ប្រអប់១: ទំនិញកកើតទាំងស្រុង
ប្រអប់២: គំរូគណនារូបមន្តដោយផ្ទាល់
ប្រអប់៣: និយមន័យ RVC
ប្រអប់៤: ការពិចារណា RVC ចំពោះមុខ CTC
ប្រអប់៥: ការបញ្ជូនទំនិញដោយត្រង់
ប្រអប់៦: តម្រូវការព័ត៌មានសម្រាប់ផ្ទៀងផ្ទាត់

## បញ្ជីតារាង

តារាង១: តើវិធាន CTC ដំណើរការដូចម្ដេច
តារាង២: ការបង្ហាញពីវិធានដោយឡែកសម្រាប់ផលិតផលដោយបញ្ជាក់ពីសង្វាក់ផលិត
តារាង៣: តម្រូវការទិន្នន័យអប្បបរមា-ការដាក់ពាក្យសុំវិញ្ញាបនបត្រដើមកំណើត
តារាង៤: តម្រូវការទិន្នន័យអប្បបរមា-វិញ្ញាបនបត្រដើមកំណើត
តារាង៥: ការប្រៀបធៀបគោលការណ៍វិធានដើមកំណើត រវាងកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន
តារាង៦: ការប្រៀបធៀបនីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រជាមួយកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានដែលបានជ្រើសយក

## បញ្ជីគំនូសតាង

គំនូសតាង១: ការអនុវត្ត CTC
គំនូសតាង២: បទប្បញ្ញត្តិ ដឺមីនីមីុសសម្រាប់ CTC
គំនូសតាង៣: ដំណាក់កាលក្នុងនីតិវិធីនៃការចេញវិញ្ញាបនបត្រ AANZFTA សម្រាប់វិធានដើមកំណើត
គំនូសតាង៤: កាលវិភាគសម្រាប់នីតិវិធីផ្ទៀងផ្ទាត់

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AANZFTA | កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ |
| ACFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន |
| AIFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា |
| AJCEP | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន |
| AKFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ |
| ATIGA | កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន |
| CC | ការប្តូរជំពូក |
| CO | វិញ្ញាបនបត្រដើមកំណើត |
| CTC | ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ |
| CTH | ការប្តូរ Heading (ចំណាត់ថ្នាក់ ៤ខ្ទង់) |
| CTSH | ការប្តូរ Subheading (ចំណាត់ថ្នាក់ ៦ ខ្ទង់) |
| FOB | លក្ខខណ្ឌប្រគល់ដល់នាវា |
| FTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| OCP | នីតិវិធីនៃការចេញវិញ្ញាបនបត្រ |
| PSR | វិធានដោយឡែកសម្រាប់ផលិតផល |
| ROO | វិធានដើមកំណើត |
| RVC | សមាសភាគតម្លៃតំបន់ |
| WO | ទំនិញកកើត/ផលិតទាំងស្រុង |



# ឯកសារដំបូងស្តីពីវិធានដើមកំណើត
# ក្នុងកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់



## ផ្នែក ១
## សេចក្តីផ្តើម

កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្រ្តាលី-ណូវែលហ្សេឡង់ ( AANZFTA) សង្ឃឹមថានឹងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១០។ វាមានសារៈសំខាន់សម្រាប់ពាណិជ្ជករ ក្នុងការទាញយកផលប្រយោជន៍ នៃឱកាសដែលបានបង្កើតដោយកិច្ចព្រមព្រៀងថ្មី ចាប់ពីថ្ងៃទីមួយនៃការអនុវត្ត។ ដើម្បីឲ្យអ្នកនាំចេញទទួលបានផលប្រយោជន៍ពីឱកាសថ្មីទាំងនេះ វាជាការចាំបាច់ណាស់ដែលពួកគេ ត្រូវយល់ដឹងពីវិធានដើមកំណើត (ROOs) សម្រាប់ AANZFTA និងជំណាក់កាលនីមួយៗដែលគេត្រូវធ្វើ ដើម្បីប្រាកដថាការនាំចេញរបស់គេស្របតាម ROOs។ គោលបំណងនៃការណែនាំនេះគឺពន្យល់ :

- ច្បាស់លាស់អ្វីទៅដែលជា ROOs
- តើពាណិជ្ជករ និង អាជ្ញាធរ បញ្ជាក់កំណត់ពីភាពអនុលោមទៅនឹង ROOs និង
- តើអាជ្ញាធរនៅក្នុងប្រទេសនាំចូលធានាអះអាងថា ROOs ត្រូវបានគោរពពេលដែលទំនិញបានមកដល់ព្រំប្រទល់។

### ហេតុអ្វីត្រូវមាន ROOs នៅក្នុង FTA?

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវបានរៀបរៀងឡើងដើម្បីជំរុញឲ្យមានការកើនឡើងពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឲ្យកាន់តែច្រើនថែមទៀតរវាង និងក្នុងចំណោមសេដ្ឋកិច្ចដែលបានចូលរួមនៅក្នុង FTA ដោយផ្តល់ដល់អ្នកនាំចេញរបស់បណ្តាភាគី នូវការបើកចំហច្រើនជាងទៅកាន់ទីផ្សាររបស់បណ្តាភាគីដទៃទៀតនៃ FTA ជាទូទៅតាមរយៈការផ្តល់ប្រព្រឹត្តិកម្មពន្ធសូន្យសម្រាប់ផលិតផលភាគច្រើន ថ្វីបើមានការកាត់បន្ថយ និងលុបពន្ធ អាចនឹងត្រូវធ្វើតាមរយៈពេលអន្តរកាលណាមួយ។ ហេតុដូច្នេះហើយ ពន្ធដែលប្រទេសដែលអនុវត្តក្រោម FTA ដែលខ្លួនជាភាគី ជាទូទៅទាបជាងពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុត។ វិធានដើមកំណើត នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដូចជា AANZFTA មានគោលដៅពីរ។ តាមរយៈ ROOs អាជ្ញាធរនៅក្នុងប្រទេសនាំចូលអាចប្រាកដថា : (១) ទំនិញដើមកំណើតនៅក្នុងបណ្តាភាគីដែលជាភាគីនៃ FTA ត្រូវផ្តល់ការនាំចូលអនុគ្រោះ ដែលមានសិទ្ធិទទួលស្របតាមការសន្យាពន្ធនៃ FTA និង (២) ទំនិញដើមកំណើត FTA មិនអាចទទួលបានការនាំចូលអនុគ្រោះដូចគ្នាឡើយ។

វាជាធម្មតាទៅហើយពីការទិទានពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថា ROO ស្មុគស្មាញ និងធ្វើឲ្យមានផលវិបាកដល់ពាណិជ្ជកម្ម ដើម្បីទទួលការនាំចូលអនុគ្រោះទៅទីផ្សារបើកចំហនៃ FTA។ វាជាការពិតណាស់ថា ROOs អាចកំណត់បានផងដែរពី FTA ដែលមានលក្ខណៈតឹងតែង ឬសេរី។ លក្ខខណ្ឌច្រើនដែលអ្នកផលិត/អ្នកនាំចេញ ត្រូវតែបំពេញដើម្បីបំពេញបានវិធានដើមកំណើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី វាមិនត្រូវទំនងថាពួកគេមានឱកាសទទួលបានការនាំចូលអនុគ្រោះ។ ROO ត្រូវតែថ្លឹងថ្លែងគោលដៅនៃការពង្រីកប្រព្រឹត្តិកម្មពន្ធអនុគ្រោះ ចំពោះតែទំនិញដែលមានដើមកំណើតនៅក្នុងភាគីប៉ុណ្ណោះ ទោះជាត្រូវធានាថា កិច្ចព្រមព្រៀងសម្រួលការកើនឡើងពាណិជ្ជកម្មរវាងបណ្តាភាគី។ ដូចនេះ ប្រភេទនៃរបប ROO មានសារៈសំខាន់។ ប៉ុន្តែវាក៏សំខាន់ផងដែរថា ក្រុមហ៊ុនបានយល់ច្បាស់ពីសង្វាក់ផលិតរបស់ខ្លួន និងត្រូវដឹងថា សង្វាក់ផលិតនោះអាចសម្របបាន បើចាំបាច់តាម ROOs។

## ទស្សនៈគន្លឹះក្នុង FTA ROOs

ទំនិញដែលបំពេញតម្រូវការវិធានដើមកំណើត ត្រូវបានស្គាល់ថា "ទំនិញដើមកំណើត" ។ ទស្សនៈគន្លឹះដែលស័ក្តិសមគឺ "ទំនិញកកើតទាំងស្រុង (ឬផលិតទាំងស្រុង) " និងទំនិញដែលចាត់ថា ទំនិញដើមកំណើត ពីព្រោះទំនិញទាំងនោះបានចេញពីសង្វាក់ផលិត "ការប្រែប្រួលដុំកំភួន"។ ទំនិញដែលជាទូទៅចាត់ទុកថា កកើតទាំងស្រុង នៅពេលដែលទំនិញទាំងនោះ ផលិតនៅក្នុងប្រទេសនាំចេញដោយប្រើវត្ថុធាតុដើមទាំងស្រុងរបស់ប្រទេសនោះ (ឧទាហរណ៍ ទំនិញដែលបានដាំដុះ បានកើត បានចិញ្ចឹម បានប្រមូល ឬបានយកចេញពីទីនោះ ដូចដែលមានចែងក្នុងបទប្បញ្ញត្តិ ស្តីពីទំនិញកកើតទាំងស្រុង។ ការនាំចេញរ៉ែ កសិផល និងផលិតផលដូចជា អាហារសមុទ្រដែលបានប្រមូលផលនៅប្រទេសនោះ ជាទូទៅច្រើនតែជាទំនិញកកើតទាំងស្រុង។ ក្នុងករណីដែលទំនិញមានវត្ថុធាតុដើម ឬផ្នែកណាមួយដែលមានដើមកំណើតពីប្រទេសទីបី វានៅតែមានលក្ខណៈពេញលេញជាទំនិញដើមកំណើត ប្រសិនបើទំនិញនោះបានឆ្លងកាត់កម្រិតប្រែប្រួលជាដុំកំភួន ដូចដែលមានចែងនៅក្នុង FTA's ROO។ ទំនិញដែលមិនបានឆ្លងកាត់កម្រិតប្រែប្រួលជាដុំកំភួន គ្រប់គ្រាន់នៅក្នុងប្រទេសនាំចេញ គឺជាទំនិញមិនមានដើមកំណើត និងមិនមានគ្រប់លក្ខណៈសម្រាប់ទទួលប្រព្រឹត្តិកម្មអនុគ្រោះក្រោមFTA។

## ការអះអាងការនាំចេញរបស់អ្នក ស្របតាមROO

បន្ថែមលើការបញ្ជាក់ថាទំនិញត្រូវបានចាត់ទុកថាជាទំនិញដើមកំណើត សម្រាប់គោលបំណង FTA កិច្ចព្រមព្រៀងត្រូវតែពន្យល់ទៅអ្នកនាំចេញ អំពីការអះអាងថាទំនិញរបស់គេអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះ។ វាក៏ចាំបាច់ណាស់ដែរក្នុងការប្រាប់ទៅអាជ្ញាធរនាំចូល អំពីឯកសារដែលតម្រូវ

សម្រាប់គាំទ្រទៅនឹងការស្នើសុំថា ការនាំចូលគឺទំនិញមានដើមកំណើតពីភាគីមួយនៃកិច្ចព្រមព្រៀង។ ក្រៅពីតម្រូវការនេះ  FTA អាចចែងថា ទំនិញដែលបាននាំចូលត្រូវតែមកជាមួយនូវឯកសារ ដូចជា វិញ្ញាបនបត្រដើមកំណើត ដែលបានចេញដោយអាជ្ញាធរដែលបានចាត់តាំង ដើម្បីគាំទ្រទៅនឹងការអះអាងថា ទំនិញទាំងនោះអាចទទួលប្រព្រឹត្តិកម្មពន្ធអនុគ្រោះ។

## ផ្នែក ២
## សេចក្តីផ្តើមនៃវិធានដើមកំណើត AANZFTA

វិធានដើមកំណើត AANZFTA ខុសគ្នាក្នុងទិដ្ឋភាពខ្លះពីរបប ROO ដែលមានស្រាប់ចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានដទៃទៀត។ ឧបសម្ព័ន្ធរង ៣ ប្រៀបធៀប ROO ដែលមានស្រាប់សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានមួយចំនួន។

### ភាពទន់ភ្លន់សម្រាប់អ្នកនាំចេញ

វិធានដើមកំណើតដែលអនុវត្តនៅក្រោម AANZFTA ត្រូវបានធ្វើឡើងតាមរបៀប ដែលអាចពង្រឹងសមត្ថភាពរបស់អ្នកនាំចេញ ទាញយកផលប្រយោជន៍ពីឱកាសក្រោម FTA ដោយផ្តល់គោលការណ៍ទន់ភ្លន់ដល់ការអះអាងស្ថានភាពទំនិញដើមកំណើត។ ភាពទន់ភ្លន់នេះ នឹងធ្វើឲ្យមានភាពងាយស្រួលសម្រាប់ទំនិញ ដើម្បីមានលក្ខណៈពេញលេញជាទំនិញដើមកំណើត ជាងការស្ថិតនៅក្រោមប្រព័ន្ធដែលមានវិធានតែមួយ។

សម្រាប់ប្រមាណ ៨៣ ភាគរយនៃបន្ទាត់ពន្ធកម្រិត ៦ខ្ទង់ (Tariff Sub-heading) AANZFTA ROO គឺផ្អែកលើគោលការណ៍សមភាព "co-equal" ហើយអ្នកនាំចេញត្រូវបានផ្តល់ជម្រើស ដើម្បីបំពេញបានដើមកំណើត តាមរយៈវិធាន "សមាសភាគតម្លៃតំបន់" ( RVC) ឬ "ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ" (CTC)។ តើវិធានទាំងនេះប្រតិបត្តិយ៉ាងដូចម្តេច មានរៀបរាប់លំអិតនៅខាងក្រោម។

សម្រាប់ ១០ ភាគរយ Tariff Sub-heading គោលការណ៍ CTC តែប៉ុណ្ណោះ ត្រូវអនុវត្ត និងប្រមាណ ១ ភាគរយ Tariff Sub-heading (វិស័យយានយន្តជាចម្បង) RVC ប៉ុណ្ណោះត្រូវអនុវត្ត។ ទំនិញកាកសំណល់ និងកម្ទេចកម្ទីដែលមានចំនួនប្រមាណ ១.៤ ភាគរយនៃ Tariff Sub-heading ត្រូវបានគ្របដណ្តប់ដោយវិធានពិសេស។ វិធានដោយឡែកសម្រាប់ផលិតផលធម្មតា មិនពាក់ព័ន្ធចំពោះ ៤.៥ ភាគរយនៃ Tariff Sub-heading ដែលត្រូវតែផលិត ឬកកើតទាំងស្រុងក្នុងតំបន់ AANZFTA។ ជាចុងក្រោយប្រមាណ ២ ភាគ ៣ នៃ Tariff Sub-heading គឺមិត្រូវប្រើតេស្តប្រតិកម្មគីមី ដើម្បីបញ្ជាក់ថាទំនិញទាំងនោះមានដើមកំណើត ប្រសិនបើទំនិញទាំងនោះ មិនបំពេញបានវិធានដើមកំណើតRVC ឬ CTC ទេ។

ភាពទន់ភ្លន់នៅក្នុងការអនុវត្ត AANZFTA ROO ត្រូវបានពង្រឹងបន្ថែមដោយបទប្បញ្ញត្តិដឺមីនីមីស និង បទប្បញ្ញត្តិការបូកផ្សំតំបន់។

## ការបូកផ្សំតំបន់: ការជំរុញសមាហរណកម្មឲ្យកាន់តែច្រើនឡើង

ការដែល AANZFTA ROO មានចែងអំពីការបូកផ្សំតំបន់ ក្នុងការគណនាដើម្បីកំណត់ពីភាពអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះ ត្រូវបានសង្ឃឹមថាមានតម្លៃធំធេងណាស់សម្រាប់វិស័យឧស្សាហកម្ម ដោយហេតុថា វានឹងជួយទ្រទ្រង់សមាហរណកម្មច្រើនឡើងទៅក្នុងសង្វាក់ផ្គត់ផ្គង់តំបន់។ ចំពោះរបប AANZFTA ROO វត្ថុធាតុដើមកំណើត ឬផ្នែកផ្សំពីប្រទេស AANZFTA ណាមួយដែលបានប្រើក្នុងការផលិតទំនិញនៅក្នុងប្រទេសសមាជិកដទៃទៀត ត្រូវបានទទួលប្រព្រឹត្តិកម្មដូចវត្ថុធាតុដើម ឬផ្នែកផ្សំពីប្រទេសទីពីរនោះ ក្នុងការកំណត់ដើមកំណើតសម្រាប់ទំនិញចុងក្រោយ។ ជាឧទាហរណ៍ - អ្នកផលិតនៅក្នុងប្រទេសវៀតណាម អាចចាត់ទុកធាតុផ្សំដែលបាននាំចូលពីប្រទេសសិង្ហបុរី និងម៉ាឡេស៊ីថាមានដើមកំណើត AANZFTA ដូចគ្នានឹងធាតុផ្សំរបស់ប្រទេសវៀតណាម ក្នុងការគណនាភាពអាចទទួលបាននូវទំនិញចុងក្រោយ ដើម្បីបំពេញការតម្រូវរបស់វិធានដើមកំណើតនៅក្នុងប្រទេសអូស្ត្រាលី។

## ទំនិញដើមកំណើតកកើតទាំងស្រុងនៅក្នុងAANZFTA

ដូចដែលបានកត់សម្គាល់ពីមុនមក ក្នុងករណីដែលទំនិញមួយចំនួន ភាពអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះក្រោមវិធានដើមកំណើត FTA គឺជាធម្មតាផ្អែកទៅលើទស្សនៈដែលទំនិញទាំងនោះ ត្រូវបានផលិត ឬកកើតទាំងស្រុងនៅក្នុងប្រទេសនាំចេញ។ AANZFTA មានបញ្ជីទំនិញដែលចាត់ទុកថាកកើតទាំងស្រុង (មើលប្រអប់ ១)។ ពាណិជ្ជកម្មដែលមានប្រមាណ ៤.៥ ភាគរយនៃ Tariff Sub-heading គឺគ្របដណ្តប់ដោយវិធានដើមកំណើតកកើតទាំងស្រុងនៃកិច្ចព្រមព្រៀង។

## ROOs ដែលបញ្ចូលតេស្តនៃការប្រែប្រួលដុំកំភួន

ចំពោះទំនិញដែលមិនកកើតទាំងស្រុង AANZFTA តម្រូវថាវាត្រូវតែស្របតាមតេស្តផ្សេងទៀត ដើម្បីប្រាកដថាវត្ថុធាតុដើមមិនមានដើមកំណើតដែលបានប្រើនៅក្នុងការផលិតផលនោះត្រូវបាន "ប្រែប្រួលជាដុំកំភួន"។ ចំពោះទំនិញភាគច្រើន (គ្របដណ្តប់ប្រមាណ ៨៣ ភាគរយនៃ Tariff Sub-heading) ត្រូវចាត់ទុកជាទំនិញដើមកំណើត ប្រសិនបើទំនិញទាំងនោះអាចបំពេញបានតាមការធ្វើតេស្តការប្តូរ

ចំណាត់ថ្នាក់បន្ទាត់ពន្ធ (CTC) ឬសមាសភាគតម្លៃតំបន់ (RVC)។ ចំពោះទំនិញដទៃទៀត មានតែការធ្វើតេស្ត RVC ឬ CTC ប៉ុណ្ណោះ ឬតេស្តថា តម្រូវការទាមទារការកែច្នៃជាក់លាក់ត្រូវបានបំពេញ។ នៅក្នុងករណីតេស្ត CTC រាល់វត្ថុធាតុដើមដែលបានប្រើសម្រាប់ការផលិតទំនិញ ដែលមិនមានដើមកំណើត AANZFTA (ឧទា. វត្ថុធាតុដើមដែលបាននាំចូលពីប្រទេសក្រៅតំបន់ AANZFTA) ត្រូវតែឆ្លងកាត់ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធតាមកម្រិតដែលបានចែង។ លំអិតច្រើនទៀតស្តីពីការអនុវត្តការធ្វើតេស្តនេះ មានផ្តល់នៅខាងក្រោម។

**ផ្នែក ៣**
**តើបទប្បញ្ញត្តិ ROO នៅក្នុង AANZFTA នៅទីណា?**

បទប្បញ្ញត្តិ ROO នៅក្នុង AANZFTA មានចែងនៅក្នុង:

- ជំពូក៣ នៃកិច្ចព្រមព្រៀង ដែលមានចំណងជើង "វិធានដើមកំណើត"
- ឧបសម្ព័ន្ធទៅនឹងជំពូក៣ ដែលមានចំណងជើង "នីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រ"។ ឧបសម្ព័ន្ធនេះរួមបញ្ចូលផងដែរឧបសម្ព័ន្ធរងពីរ ដែលមានចែងពីតម្រូវការទិន្នន័យអប្បបរមាសម្រាប់ :
    - ការអនុវត្ត CO
    - វិញ្ញាបនបត្រដើមកំណើត និង
- ឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង ដែលមានចំណងជើង "វិធានដោយឡែកសម្រាប់ផលិតផល"

ភាគីទាំងអស់បានឯកភាពគ្នាទៅវិញទៅមកលើទម្រង់ CO ដែលនឹងត្រូវប្រើប្រាស់ដោយស្ថាប័នចេញវិញ្ញាបនបត្រ។

ចំពោះផលិតផលដែលគ្របដណ្តប់ដោយ Tariff Sub-heading ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២ ស្តីពីវិធានដោយឡែកសម្រាប់ផលិតផល (PSR) វិធានដើមកំណើតសម្រាប់វា មានចែងនៅក្នុងឧបសម្ព័ន្ធនោះ។ ចំពោះផលិតផលដែលគ្របដណ្តប់ដោយ Tariff Sub-heading ដែលមិនមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២ ត្រូវអនុវត្តវិធានទូទៅ។ វិធានទូទៅនេះមានចែងក្នុងមាត្រា ៤.១ នៃជំពូកវិធានដើមកំណើត និងចែងថា ទំនិញមួយនឹងត្រូវចាត់ទុកថាមានដើមកំណើត AANZFTA ប្រសិនបើទំនិញនោះស្របទៅតាមតេស្តដូចខាងក្រោម :

- ទំនិញមាន RVC មិនតិចជាង ៤០ ភាគរយនៃតម្លៃ FOB (តម្លៃប្រគល់ដល់នាវា) និងសង្វាក់ផលិតចុងក្រោយនៃផលិតផលនោះ ត្រូវធ្វើឡើងនៅក្នុងភាគី។
- រាល់វត្ថុធាតុដើមដែលមិនមានដើមកំណើត ប្រើនៅក្នុងការផលិតទំនិញ ត្រូវឆ្លងកាត់ការប្តូរ CTC កម្រិត ៤ ខ្ទង់ (ឧទា. ការប្តូរបន្ទាត់ពន្ធកម្រិត ៤ ខ្ទង់)។

## ផ្នែក ៤
## តើទីណាដែលអាចរកឃើញ ROO សម្រាប់ទំនិញជាក់លាក់

ដើម្បីរកឃើញវិធានដើមកំណើត AANZFTA សម្រាប់ទំនិញជាក់លាក់ ជំហានខាងក្រោមនេះត្រូវតែប្រតិបត្តិតាម :

**ជំហានទី១** : ពិនិត្យ ថាតើទំនិញនោះបានបំពេញទៅនឹងតម្រូវការ AANZFTA សម្រាប់ទំនិញកកើត ឬផលិតទាំងស្រុង ដូចដែលមានចែងនៅក្នុងមាត្រា៣ នៃជំពូកវិធានដើមកំណើត (មើលប្រអប់១) ឬវាបានផលិតនៅក្នុងភាគីតែមួយ ដោយប្រើវត្ថុធាតុដើមកំណើតទាំងអស់ពីភាគីមួយ ឬច្រើន អនុលោមតាមមាត្រា ២.១ (គ) នៃជំពូកវិធានដើមកំណើត។ ប្រសិនបើទំនិញបានបំពេញតម្រូវការទាំងនោះ ដូចនេះទំនិញជាទំនិញមានដើមកំណើត AANZFTA។ ប្រសិនបើទំនិញមិនបានបំពេញតម្រូវការទាំងនោះទេ សូមចូលទៅជំហានទី២។

**ជំហានទី២**: ពិនិត្យ ថាតើទំនិញបានគ្របដណ្តប់ដោយវិធានដោយឡែកនៃកិច្ចព្រមព្រៀងសម្រាប់ផលិតផល ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ២។ ប្រសិនបើទំនិញបានគ្របដណ្តប់ដោយ Tariff Sub-heading ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២ នោះវាត្រូវតែបំពេញ PSR ដែលមានចែងនៅក្នុងជួរទី៤ នៃឧបសម្ព័ន្ធ ដើម្បីត្រូវបានចាត់ទុកថាទំនិញដើមកំណើត។ ប្រសិនបើទំនិញមិនបានគ្របដណ្តប់ដោយឧបសម្ព័ន្ធ ២ ទេ សូមចូលទៅជំហានទី៣។

**ជំហានទី៣** : ចំពោះទំនិញដែលមិនបានគ្របដណ្តប់ដោយជំហានទី១ និងទី២ វិធានទូទៅដែលមានចែងនោះក្នុងមាត្រា ៤ .១ នៃជំពូកវិធានដើមកំណើតត្រូវអនុវត្ត។ វិធានទូទៅនេះចែងថា ទំនិញចាត់ទុកថាមានដើមកំណើត AANZFTA ប្រសិនបើទំនិញនោះ បានបំពេញទៅនឹងការធ្វើតេស្តណាមួយនៃ RVC ឬ CTC : វាត្រូវមាន RVC មិនតិចជាង ៤០ ភាគរយ និងសង្វាក់ផលិតចុងក្រោយត្រូវប្រព្រឹត្តទៅនៅក្នុងភាគី AANZFTA ឬវត្ថុធាតុដើមមិនមានដើមកំណើតដែលបានប្រើក្នុងការផលិត ត្រូវឆ្លងកាត់ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិត ៤ខ្ទង់ (ដូចជាការប្តូរ Tariff Heading)។

ផ្នែក៥ និង៦ នៃការណែនាំ ពន្យល់លំអិតពីការប្រើការធ្វើតេស្តសមាសភាគតម្លៃតំបន់ និងការធ្វើតេស្តការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ (CTC) ដែលប្រើក្នុង AANZFTA។

## ប្រអប់ ១: ទំនិញកកើតទាំងស្រុង

មាត្រា៣ នៃជំពូកវិធានដើមកំណើត AANZFTA រៀបរាប់ ទំនិញកកើតទាំងស្រុងៈ

- រុក្ខជាតិ និងផលិតផលពីរុក្ខជាតិរួមទាំង ផ្លែឈើ ផ្កា បន្លែ ដើមឈើ សារាយសមុទ្រ ផ្សិត និងរុក្ខជាតិមានជីវិត ដាំដុះ ច្រូតកាត់ បេះ ឬប្រមូល នៅក្នុងភាគី
- សត្វរស់ដែលកើត និងចិញ្ចឹមនៅក្នុងភាគី
- ទំនិញដែលបានមកពីសត្វរស់នៅក្នុងភាគី
- ទំនិញដែលបានមកពីការបរបាញ់ ដាក់អន្ទាក់ នេសាទ ដាំដុះ ឬវារីវប្បកម្ម ប្រមូល ចាប់បាននៅក្នុងភាគី
- រ៉ែ និងសារធាតុដែលកើតមកតាមលក្ខណៈធម្មជាតិដទៃទៀត ដែល យកចេញពីដី ទឹក បាតសមុទ្រ ឬ ក្រោមបាតសមុទ្រ របស់ភាគី
- ទំនិញពីការនេសាទសមុទ្រ និងផលិតផលពីសមុទ្រផ្សេងៗទៀតដែល ចាប់បានពីសមុទ្រអន្តរជាតិ អនុលោមទៅតាមច្បាប់អន្តរជាតិ ដោយនាវាដែលបានចុះបញ្ជី ឬកត់ត្រាទុក នៅក្នុងភាគី និងមានសិទ្ធិបង្ហោះទង់ជាតិនៃភាគីនោះ
- ទំនិញដែលបានផលិតនៅលើនាវារោងចក្រ ដែលបានចុះបញ្ជី និងបានកត់ត្រានៅក្នុងភាគី និងមានសិទ្ធិបង្ហោះទង់ជាតិរបស់ភាគីនោះ សម្រាប់ទំនិញដែលមានចែងនៅចំណុចខាងលើ
- ទំនិញដែលយកបានដោយភាគី ឬបុគ្គលនៃភាគី ពីបាតសមុទ្រ ឬក្រោមបាតសមុទ្រក្រៅតំបន់សេដ្ឋកិច្ចពិសេស និងជាប់ជាមួយនឹងស្រទាប់ទ្វីបនៃភាគីនោះ និងក្រៅតំបន់នោះដែលភាគីទីបីមានសិទ្ធិគ្រប់គ្រងក្រោមសិទ្ធិអាជីកម្ម ដែលផ្តល់ដោយច្បាប់អន្តរជាតិ
- ទំនិញដែលជា :
  - កម្ទេច និងកាកសំណល់បានមកពីការផលិត និងការប្រើប្រាស់នៅក្នុងភាគី ឲ្យតែទំនិញសម្រាប់តែទាញយកវត្ថុធាតុដើមមកវិញ ឬ
  - ទំនិញដែលប្រើរួច ប្រមូលនៅក្នុងភាគី ឲ្យតែទំនិញសម្រាប់តែទាញយកវត្ថុធាតុដើមវិញ និង
- ទំនិញផលិត ឬ កកើតនៅភាគី ពីផលិតផលដែលមានចែងនៅក្នុងចំណុចទាំងអស់ខាងលើ ឬពីទំនិញ ចេញពីទំនិញទាំងនោះ។

## ផ្នែក ៥
## ការគណនាសមាសភាគតម្លៃតំបន់ (RVC)

ដូចដែលបានកត់សម្គាល់ពីមុនមក ស្ថានភាពដើមកំណើតទំនិញអាចកំណត់បានចំពោះ ៨៣ ភាគរយនៃបន្ទាត់ពន្ធទាំងអស់របស់ AANZFTA តាមរយៈវិធី CTC ឬការគណនា RVC។ បន្ទាត់ពន្ធ Tarff Sub-heading ១ ភាគរយទៀតតម្រូវឲ្យប្រើតែវិធី RVC។ នៅក្នុង AANZFTA មានវិធីពីរយ៉ាងដែលអាចប្រើសម្រាប់គណនា RVC : ការគណនា "រូបមន្តដោយផ្ទាល់" និងការគណនា "រូបមន្តដោយប្រយោល/Build Down"។ នៅស្ទើរតែគ្រប់ករណីទាំងអស់ RVC ត្រូវតែស្មើ យ៉ាងតិចបំផុត ៤០ ភាគរយនៃតម្លៃទំនិញដឹកដល់នាវា (FOB) មុនពេលដែលវាចាត់ទុកថាជាទំនិញដើមកំណើតក្រោមវិធានដើមកំណើត AANZFTA។

ការគណនាដែលខុសគ្នាទាំងពីរ ត្រូវធ្វើឡើងនៅផ្នែកខាងក្រោយ ដោយបំពេញដោយឧទាហរណ៍នៃការគណនា។ នៅក្នុងឧបសម្ព័ន្ធរង២ យើងមានផ្តល់លំហាត់មួយចំនួនដែលអ្នកអានអាចធ្វើដោយខ្លួនគេផ្ទាល់ ដើម្បីយល់ដឹងពីវិធីសាស្ត្រគណនា។

### រូបមន្តដោយផ្ទាល់

ការគណនារូបមន្តដោយផ្ទាល់ធ្វើដូចខាងក្រោម :

$$\text{RVC} = \frac{\text{ថ្លៃវត្ថុធាតុ AANZFTA} + \text{ថ្លៃពលកម្ម} + \text{ថ្លៃផលិត ផ្សេងៗ} + \text{ប្រាក់ចំណេញ} + \text{ថ្លៃផ្សេងៗ}}{\text{FOB}} \times ១០០\%$$

### ប្រអប់២ : គំរូគណនារូបមន្តដោយផ្ទាល់

សហគ្រាសវៀតណាមមួយ ផលិតកៅអីសម្រាប់អង្គុយលេងខាងក្រៅ ដែលមួយឈុតមានកៅអី៤ លក់តម្លៃ ១ ,៨០០,០០០ដុង។ សហគ្រាសនាំចូលឈើមិនទាន់កែច្នៃ និងខ្ចៅដែកពីចិន មានតម្លៃ ១,០៥២,០០០ដុង។ គ្រឿងជ័រ នាំចូលពីសឹង្ហបុរី ដែលជាវត្ថុធាតុដើមមានដើមកំណើត AANZFTA មានតម្លៃ ២៨៥ ,០០០ដុង ដែករឹងលោហៈមកពីណូវ៉ែលហ្សេឡង់ ដែលជាវត្ថុធាតុដើមមានដើមកំណើត AANZFTA មានតម្លៃ ១៦៩ ,០០០ដុង និងសហគ្រាសខ្លួនឯង ផលិតកៅអីផ្តៅពីវត្ថុធាតុដើមរបស់វៀតណាមមានតម្លៃ ១៦០,០០០ដុង សម្រាប់កៅអីមួយឈុត។ ថ្លៃពលកម្មក្នុងការផលិតកៅអីមួយឈុតមាន ៤៤,៥០០ដុង ថ្លៃផលិត ២៧,០០០ដុង ថ្លៃដឹកជញ្ជូនដល់សមុទ្រហាយហ្វុង និងលើកដាក់នាវា ៩ ,០០០ដុង សម្រាប់មួយឈុត និងក្រុមហ៊ុនមានគម្រោង ប្រាក់ចំណេញ ៣ភាគរយ (៥៣,៣០០ដុង) លើការលក់ផលិតផល។ តើកៅអីមួយឈុតដែលមាន ៤កៅអី បំពេញបាន RVC ដែរឬ ទេ?

២៨៥,០០០

១៦៩ ,០០០

១៦០ ,០០០ + ៤៤,៥០០ + ២៧,០០០ + ៥៣,៣០០ + ៩,០០០ = ៧៤៧ ,៨០០

RVC = ———————— ———— X ១០០%

១ ,៨០០,០០០ ១ ,៨០០,០០០

RVC= ៤១, ៥%

ដូចនេះ កៅអីមួយឈុតបានបំពេញវិធាន RVC ៤០% ក្រោម AANZFTA និងជា "ទំនិញដើមកំណើត"

## រូបមន្តដោយប្រយោល/Build-Down

នៅក្នុងករណីដែលអាចធ្វើទៅបាន សហគ្រិនត្រៀមជាស្រេច និងច្បាស់លាស់ក្នុងការកំណត់តម្លៃវត្ថុធាតុមិនមានដើមកំណើតប្រើក្នុងការផលិតទំនិញ វិធានដើមកំណើត AANZFTA អនុញ្ញាតឲ្យប្រើការគណនារូបមន្តដោយប្រយោល/Build –Down ដែលការគណនានេះមាន:

$$RVC = \frac{\text{FOB - តម្លៃវត្ថុធាតុមិនមែនដើមកំណើត}}{\text{FOB}} \times ១០០\%$$

ប្រសិនបើយើងប្រើរូបមន្តនេះ ដោយឧទាហរណ៍សហគ្រាសផលិតកៅអីវៀតណាម នៅក្នុងប្រអប់ ៣ និងសន្មតថាសហគ្រាសអាចមានគណនីច្បាស់លាស់ ១,០៥២,២០០ សម្រាប់ការនាំចូលឈើ និងខ្ចៅដែកពីចិន យើងអាចគណនាដូចខាងក្រោម:

$$\text{RVC} = \frac{\text{១,៨០០,០០០ - ១,០៥២,២០០}}{\text{១,៨០០,០០០}} = \frac{\text{៧៤៧,៨០០}}{\text{១,៨០០,០០០}} \text{ X ១០០\% = ៤១.៥\%}$$

កត់សម្គាល់ថា នៅក្នុងឧទាហរណ៍ យើងបានប្រើការបញ្ជាក់ពីការគណនា RVC វិធានដើមកំណើត AANZFTA ស្តីពីវិធានបូកផ្សំ អនុញ្ញាតឲ្យសហគ្រាសផលិតកៅអីវៀតណាម ប្រើធាតុចូលពីសឹង្ហបុរី និងណូវែលហ្សេឡង់ដូចគ្នាទៅនឹងធាតុចូលដែលផលិតដោយសហគ្រាស។ ម៉្យាងវិញទៀត នេះគឺជាករណីមួយប៉ុណ្ណោះ ដែលធាតុចូលពីសឹង្ហបុរី និងណូវែលហ្សេឡង់បំពេញបានវិធានដើមកំណើត AANZFTA ហេតុដូចនេះហើយ បានជាទំនិញនោះជាទំនិញមានដើមកំណើត AANZFTA។

### ប្រអប់៣ : និយមន័យ RVC

**ថ្លៃវត្ថុធាតុដើម AANZFTA** = ថ្លៃវត្ថុធាតុដើមមានដើមកំណើតមាន វត្ថុធាតុដើម ផ្នែក ឬផលិត ដែលតម្រូវ ឬផលិតដោយខ្លួនឯងដោយអ្នកផលិត ក្នុងការផលិតទំនិញ

**ថ្លៃពលកម្ម** = ប្រាក់ខែ លាភការ និងប្រាក់ចំណេញផ្សេងរបស់និយោជិត

**ថ្លៃសរុប** = សរុបការចំណាយក្នុងការផលិតទាំងអស់របស់អ្នកផលិត

**ថ្លៃផ្សេងៗ** = ថ្លៃសម្រាប់ដាក់ទំនិញចូលនាវា ឬមធ្យោបាយដឹកជញ្ជូនសម្រាប់ការនាំចេញ រួមមាន តែមិនចំពោះថ្លៃដឹកជញ្ជូនក្នុងស្រុក រក្សាទំនិញទុកក្នុងឃ្លាំង លើកដាក់នៅកំពង់ផែ ចំណាយសម្រាប់អ្នករត់ការ និងសេវាផ្សេងៗ

**FOB** = ថ្លៃដល់នាវា រួមទាំងថ្លៃដឹកជញ្ជូនដល់នាវា ឬទីតាំងចុងក្រោយនៃការដឹកជញ្ជូនទៅក្រៅប្រទេស។ ថ្លៃនេះត្រូវតែអនុលោមតាម GATT នៃតម្លៃគិតពន្ធគយ

**ថ្លៃវត្ថុធាតុដើមមិនមានដើមកំណើត**= ថ្លៃដឹកជញ្ជូនដែលរួមទាំងធានារ៉ាប់រង នៅពេលនាំចូល ឬថ្លៃដែលបានចំណាយដំបូងលើវត្ថុធាតុដើមមិនមានដើមកំណើត វត្ថុធាតុដើមផ្នែក ឬផលិត ដែលតម្រូវដោយអ្នកផលិត សម្រាប់ផលិតទំនិញ។ វត្ថុធាតុដើមមិនមានដើមកំណើត ប៉ុន្តែមិនរាប់បញ្ចូលវត្ថុធាតុដើម ដែលផលិតដោយខ្លួនឯង

**CIF** = ថ្លៃទំនិញនាំចូល និងរួមទាំងថ្លៃដឹកជញ្ជូន និងធានារ៉ាប់រងដល់កំពង់ផែ ឬទីកន្លែងនៃច្រកចូល ប្រទេសនាំចូល។ ថ្លៃនេះត្រូវតែអនុលោមតាម GATT នៃតម្លៃគិតពន្ធគយ។

## ការកែច្នៃ និងការប្រតិបត្តិតិចតួច

ការកែច្នៃ និងការប្រតិបត្តិមួយចំនួនមិនរាប់បញ្ចូលក្នុងការបំពេញបាន RVC ក្រោមវិធានដើមកំណើត AANZFTA ទេ។ ទោះបីជាការកែច្នៃបែបនេះធ្វើឡើងដោយមួយប្រភេទ ឬច្រើនប្រភេទ ឬបញ្ចូលជាមួយផលិតផលដទៃទៀតបញ្ចូលគ្នាក៏ដោយ ក៏ការកែច្នៃខាងក្រោមនេះមិនត្រូវបានចាត់ចូលសម្រាប់ការគណនា RVC ទេ :

- សម្រាប់រក្សាទំនិញឲ្យស្ថិតក្នុងលក្ខខណ្ឌមួយល្អ សម្រាប់គោលបំណងដឹកជញ្ជូន ឬរក្សាទុក
- សម្រួលដល់ការលើកដាក់ ឬដឹកជញ្ជូន
- វេចខ្ចប់ (មិនរាប់បញ្ចូលការវេចខ្ចប់ដោយឧស្សាហកម្មអេឡិចត្រូនិក) ឬការបង្ហាញទំនិញសម្រាប់ដឹកជញ្ជូន ឬលក់
- ការប្រតិបត្តិសាមញ្ញរួមមាន ការផ្លាស់ប្តូរទីកន្លែង ការចាត់ចំណាត់ថ្នាក់ បោកគក់ កាត់ វះ បត់ មូរ និងពន្លា និងការប្រតិបត្តិប្រហាក់ប្រហែលផ្សេងទៀត
- បិទស្លាក យីហោ ឬសញ្ញាសម្គាល់ផ្សេងទៀតលើផលិតផល ឬសំបកវេចខ្ចប់ និង
- គ្រាន់តែលាយជាមួយទឹក ឬសារធាតុផ្សេងទៀត ដោយមិនផ្លាស់ប្តូរចរិតលក្ខណៈនៃទំនិញ។

### ប្រអប់៤ : ការពិចារណា CTC ចំពោះមុខ RVC

នៅក្នុងចំណុចនេះ វាជាការសំខាន់ណាស់ក្នុងការបញ្ជាក់ឡើងវិញថា មានការអនុញ្ញាតពិសេសមួយចំនួន តាមរបៀប CTC តែមិនអនុញ្ញាតក្រោមការគណនា RVC។

ក្រោម CTC វិធាន **ដឺមីនីម៉ុស** អាចមាន ១០ភាគរយ នៃតម្លៃទំនិញ ដែលអាចចាត់ទុកថាជាវត្ថុធាតុដើមមិនមានដើមកំណើត ដែលមិនឆ្លងកាត់ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ។ គ្មានវិធានដឺមីនីម៉ុសណាមួយ អនុវត្តក្នុងករណីគណនាRVC ឡើយ។

ក្រោមរបៀប CTC **គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍**ដែលមានវត្តមានជាមួយទំនិញ និងមិនស្ថិតនៅក្នុងវិក្កយបត្រដាច់ដោយឡែក ដែលជាទូទៅមិនគិតចូលសម្រាប់គោលបំណងកំណត់ CTC យ៉ាងណាមិញ តម្លៃទាំងនេះត្រូវចូលរួមសម្រាប់គោលបំណងគណនា RVC។

ក្រោមរបៀប CTC **វត្ថុធាតុវេចខ្ចប់ និងភាជន៍ (កុងតឺន័រ)** ដែលទំនិញត្រូវខ្ចប់សម្រាប់ការលក់រាយ-នៅពេលចាត់ចូលចំណាត់ថ្នាក់តែមួយជាមួយទំនិញ-មិនត្រូវបានយកមកកំណត់ថា វត្ថុធាតុដើមមិនមានដើមកំណើតទាំងអស់ ដែលបានប្រើក្នុងការផលិតទំនិញបានបំពេញតាមតម្រូវការការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធទេ។ ប៉ុន្តែពេលគណនា RVC តម្លៃវត្ថុធាតុវេចខ្ចប់ និងភាជន៍ (កុងតឺន័រ) ត្រូវបានចាត់ទុកថាជាដើមកំណើត ឬមិនមានដើមកំណើត។

## ផ្នែក ៦
## ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ

ទស្សនៈពី CTC អនុវត្តចំពោះតែវត្ថុធាតុដើមមិនមានដើមកំណើត។ ដើម្បីបំពេញបានតម្រូវការ CTC វត្ថុធាតុដើមមិនមានដើមកំណើត និងធាតុផ្សំប្រើក្នុងការផលិតទំនិញដទៃទៀត មិនត្រូវស្ថិតនៅក្រោមចំណាត់ថ្នាក់ក្នុងប្រព័ន្ធសុខដុមដូចគ្នានឹងទំនិញចុងក្រោយ ដែលវត្ថុធាតុដើមនោះបានដាក់បញ្ចូល។ វិធាន CTC ត្រូវបានសរសេរឡើងដើម្បីធានាថា តម្រូវការផ្លាស់ប្តូរវត្ថុធាតុដែលមិនមានដើមកំណើតកើតឡើងនៅក្នុងដែនដីភាគី FTA ដើម្បីទាមទារថាទំនិញបានផលិតនៅក្នុងដែនដី FTA។

យើងអាចលើកឧទាហរណ៍ ដើម្បីឲ្យឃើញពីរបៀប CTC អាចអនុវត្តតាមការជាក់ស្តែង។ ឧទាហរណ៍ថា ក្រុមហ៊ុនមានមូលដ្ឋាននៅប្រទេសម៉ាឡេស៊ី ផលិតម៉ាស៊ីនបោសសំអាត ដែលម៉ាស៊ីននេះនឹងលក់នៅលើទីផ្សារអូស្ត្រាលី និងណូវ៉ែលហ្សេឡង់។ ម៉ាស៊ីនបោសសំអាតបានផលិតដោយក្រុមហ៊ុនមានចំណាត់ថ្នាក់ HS ជំពូករង ៨៥០៨ និងក្រោម Subheading ៨៥០៨.១១។ វិធានដើមកំណើត AANZFTA សម្រាប់ម៉ាស៊ីនបោសសំអាតមានលក្ខណៈទន់ភ្លន់ ដែលអាចបំពេញបានតាមវិធាន CTC (Tariff Sub-heading) វិធាន RVC ( មាន RVC យ៉ាងតិច ៤០ ភាគរយ) ឬវិធានទាំងពីរបញ្ចូលគ្នា (Tariff Sub-heading ដរាបណាទំនិញត្រូវមាន RVC យ៉ាងតិច ៣៥ ភាគរយ)។ សហគ្រាសផលិតម៉ាស៊ីនបោសសំអាតរបស់ម៉ាឡេស៊ីអាចទិញវត្ថុធាតុ និងផ្នែកផ្សំពីក្នុងប្រទេស ឬទិញពីតំបន់ AANZFTA ដទៃទៀត ប៉ុន្តែក្រុមហ៊ុនយល់ឃើញថា សំខាន់ណាស់ក្នុងការទិញ Steel Springs ពីចិន ( HS ៧៣២០) ម៉ូទ័រអគ្គិសនី (HS ៨៥១២) ពីជប៉ុន និងបាដាង (HS ៨៤៨២) ពីអាល្លឺម៉ង់។

នៅក្រោម AANZFTA ម៉ាស៊ីនបោសសំអាតនាំចេញទៅអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ គ្រប់លក្ខណៈជាទំនិញដើមកំណើតពីម៉ាឡេស៊ីក្រោមវិធាន CTC ពីព្រោះបាននាំចូលវត្ថុធាតុដើមមិនមែនដើមកំណើតដែលមានចំណាត់ថ្នាក់តាមជំពូករងផ្សេងគ្នាពីជំពូករង ៨៥០៨ ដែលជាម៉ាស៊ីនបោសសំអាត។ ទំនិញអាចគ្រប់លក្ខណៈតាមការធ្វើតេស្តមួយ ក្នុងចំណោមការធ្វើតេស្តពីរទៀតដែលមានស្រាប់ សម្រាប់ទំនិញនៃ Tariff Sub-heading ៨៥០៨.១១ តែមិនចាំបាច់មានតម្រូវការធ្វើតេស្ត ដោយវិធានដើមកំណើត AANZFTA បានបញ្ជាក់ថា ទំនិញគ្រាន់តែបំពេញទៅនឹងជម្រើសការធ្វើតេស្តមួយណាក៏បាន ប្រសិនបើទំនិញនោះស្ថិតនៅក្នុងការសង្ស័យ។

**គំនូសតាង ១**

**ការអនុវត្ត CTC**




ក្នុងករណីជាច្រើន វិធានដោយឡែកសម្រាប់ផលិតផល ដែលធ្វើពាណិជ្ជកម្មក្រោម AANZFTA បញ្ជាក់ថា ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធត្រូវតែមានការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិតជំពូក (២ខ្ទង់)។ ចំពោះករណីច្រើនទៀត ត្រូវតែមានការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិតជំពូករង (៤ ខ្ទង់)។ ចំពោះផលិតផលខ្លះការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធបានបញ្ជាក់ក្នុងកម្រិត ៦ខ្ទង់ (ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិត Tariff Sub-heading)។ ឧទាហរណ៍មួយចំនួនបានដកស្រង់ពីឧបសម្ព័ន្ធ ២ នៃ AANZFTA អាចបង្ហាញពីករណីខាងលើ។

## តារាង ១
## តើវិធាន CTC ដំណើរការដូចម្តេច

| ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិតជំពូក ២ខ្ទង់ "CC" | | | |
|---|---|---|---|
| **ជំពូករង** | **អនុជំពូករង** | **ឈ្មោះទំនិញ** | **វិធានដោយឡែកសម្រាប់ផលិតផល** |
| ៥៨០៦ | ៥៨០៦.៣១ | ក្រណាត់ត្បាញផ្សេងទៀត: ពីកប្បាស | CC |

ជំពូកកម្រិត ២ខ្ទង់ "៥៨" "គឺជាក្រណាត់ធ្មេញឈើតូច "។ អំបោះកប្បាសមួយសរសៃពីសរសៃសិតរួច ដែលជាធាតុចូលសម្រាប់ការធ្វើក្រណាត់ត្បាញចាត់នៅក្នុងជំពូក៥២ "អំបោះពីកប្បាស" (ឧទាហរណ៍ ៥២០៦.២៥)។ ការផ្លាស់ប្តូរអំបោះពីកប្បាសដែលមិនមានដើមកំណើត ឲ្យទៅជាក្រណាត់ត្បាញពី កប្បាស ធ្វើឲ្យក្រណាត់ក្លាយជាផលិតផលមានដើមកំណើតក្រោម AANZFTA។

| ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិតជំពូក ២ខ្ទង់ "CC" | | | |
|---|---|---|---|
| **ជំពូករង** | **អនុជំពូករង** | **ឈ្មោះទំនិញ** | **វិធានដោយឡែកសម្រាប់ផលិតផល** |
| ៧៣២១ | ៧៣២១.១២ | បរិធានចម្អិនអាហារ និងកំដៅអាហារ : ប្រើគ្រឿងឆេះរាវ | RVC (40) ឬ CTH ឬ RVC (35) + CTSH |

ជំពូករងកម្រិត ៤ខ្ទង់ "៧៣២១" ក្រុម "ចង្ក្រាន ប្រដាប់អាំងសាច់ និងគ្រឿងប្រដាប់ប្រហាក់ប្រហែល"។ ផលិតកម្មនៃឧបករណ៍សម្រាប់ចម្អិនដែលចាត់នៅក្នុង ៧៣២១ ដោយមិនមានការសង្ស័យថា រួមមាន ទាំងការប្រើវីសពីដែក ឬដែកថែបដែលចាត់នៅក្នុង ៧៣១៨ និង ទុយោចាត់នៅក្នុង ៧៣០៤។ ទំនិញ ទាំងនេះអាចជាវត្ថុធាតុមិនមានដើមកំណើត និងបញ្ចូលឧបករណ៍សម្រាប់ចម្អិន ដែលចាត់នៅក្នុង ៧៣២១ ជាមួយឧបករណ៍សម្រាប់ចម្អិនមានដើមកំណើតក្រោម AANZFTA។

| ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិតជំពូក ២ខ្ទង់ "CC" | | | |
|---|---|---|---|
| **ជំពូករង** | **អនុជំពូករង** | **ឈ្មោះទំនិញ** | **វិធានដោយឡែកសម្រាប់ផលិតផល** |
| ៨៤៦៧ | ៨៤៧៦.១១ | ឧបករណ៍ប្រើខ្យល់: ប្រភេទវិល (ព្រមទាំងវិលទ្រគោះ) | RVC (40) ឬ CTSH |

Tariff Sub-heading កម្រិត ៦ខ្ទង់ សម្រាប់ឧបករណ៍ប្រើខ្យល់ដោយដៃ អាចរួមបញ្ចូលគ្រឿងបន្លាស់នៃឧបករណ៍ប្រើខ្យល់ (ដែលចាត់នៅក្នុង ៨៤៦៧.៩២) និងគ្រឿងបន្លាស់ផ្សេងទៀត (ដែលចាត់នៅក្នុង ៨៤៦៧.៩៩)។ ប្រសិនបើសហគ្រាសផលិត ត្រូវទិញគ្រឿងបន្លាស់មិនមានដើមកំណើត ដែលចាត់នៅក្នុង ៨៤៦៧.៩២ និង ៨៤៦៧.៩៩ និងបន្ទាប់មកបញ្ចូលគ្នាទៅក្នុងឧបករណ៍ប្រើដោយដៃ ដែលចាត់នៅក្នុង ៨៤៦៧.១១ នោះផលិតផលចុងក្រោយពេលនាំចេញទៅទីផ្សារ AANZFTA គឺជាផលិតផលដើមកំណើតសម្រាប់គោលបំណង AANZFTA។

## ភាពទន់ភ្លន់នៃ CTC ក្រោម AANZFTA : បទប្បញ្ញត្តិដឹមីនីមុីស

សម្រាប់អ្នកនាំចេញដែលមានបំណងប្រើគោលការណ៍ CTC វិធានដើមកំណើតក្រោម AANZFTA ផ្តល់ភាពទន់ភ្លន់បន្ថែមតាមរយៈបទប្បញ្ញត្តិដឹមីនីមុីស។ បទប្បញ្ញត្តិដឹមីនីមុីសមិនអនុវត្តចំពោះគោលការណ៍ RVC ទេ។

ក្រោមបទប្បញ្ញត្តិដឹមីនីមុីស ទំនិញដែលមិនបានបំពេញតម្រូវការ CTC ទាំងស្រុង យ៉ាងណាក៏ដោយ ក៏អាចគ្រប់លក្ខណៈជាទំនិញដើមកំណើត ប្រសិនបើ :

- តម្លៃវត្ថុធាតុទាំងអស់មិនមានដើមកំណើត ដែលបានប្រើប្រាស់នៅក្នុងការផលិតទំនិញក្រៅពីផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌដែលគ្របដណ្តប់ចាប់ពីជំពូក ៥០-៦៣ ដែលមិនបានប្តូរតម្រូវការចំណាត់ថ្នាក់បន្ទាត់ពន្ធ ហើយមិនលើស ១០% តម្លៃ FOB នៃទំនិញនោះ ហើយទំនិញនោះបានបំពេញគ្រប់លក្ខខណ្ឌទាំងអស់ទៅនឹងតម្រូវការវិធានដើមកំណើតទំនិញរបស់ AANZFTA។
- ក្នុងករណីផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌដែលមាននៅក្នុង HS Code ជំពូក៥០ ដល់៦៣ :
    - ទម្ងន់វត្ថុធាតុដើមមិនមានដើមកំណើត ដែលប្រើក្នុងការផលិតទំនិញនោះមិនបានរងការប្តូរតម្រូវនៃចំណាត់ថ្នាក់បន្ទាត់ពន្ធ ហើយមិនលើស ១០% នៃទម្ងន់សរុបរបស់ទំនិញក៏បានឬ
    - តម្លៃនៃវត្ថុធាតុមិនមានដើមកំណើតទាំងអស់ប្រើនៅក្នុងការផលិតទំនិញ មិនបានរងការប្តូរតម្រូវនៃចំណាត់ថ្នាក់បន្ទាត់ពន្ធ ហើយមិនលើស ១០% តម្លៃ FOB នៃទំនិញក៏បាន។

និងទំនិញបំពេញគ្រប់លក្ខខណ្ឌតម្រូវការផ្សេងទៀតក្រោមវិធានដើមកំណើត AANZFTA។

### គំនូសតាង ២
### បទប្បញ្ញត្តិដឹមីនីមីុសសម្រាប់CTC

| ផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ | វិធានCTC ដទៃទៀត-ផលិតផលដែលអាច |
|---|---|
| (ក) តម្លៃ FOB នៃទំនិញ<br>ចុងក្រោយ = $ ១,០០០<br><br>តម្លៃធាតុចូលដែលមិន<br>ប្តូរ CTC =<$ ១០០<br><br>**ឬ**<br><br>(ខ) ទម្ងន់នៃផលិតផលចុងក្រោយ<br>= ១,៥០០គីឡូក្រាម<br><br>ទម្ងន់នៃធាតុចូលមិន<br>ប្តូរ CTC<br>=< ១៥០គីឡូក្រាម | (ក) តម្លៃ FOB នៃទំនិញ<br>ចុងក្រោយ = $ ១,០០០<br><br>តម្លៃធាតុចូលដែលមិន<br>ប្តូរ CTC =<$ ១០០ |

## ប្រព្រឹត្តិកម្មសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់និងឧបករណ៍ផ្សេងៗ

ក្រោមគោលការណ៍ CTC នៅក្នុង AANZFTA សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ និង ឧបករណ៍ និង ឯកសារការណែនាំ ឬឯកសារព័ត៌មានដែលភ្ជាប់ជាមួយនឹងទំនិញ - ក្នុងស្ថានការណ៍ជាក់លាក់ខ្លះ - បានចាត់ទុកថាជាផ្នែកមួយនៃទំនិញ និងដកចេញពេលដែលធ្វើការកំណត់ថាវត្ថុធាតុមិនមានដើមកំណើតទាំងអស់ដែលប្រើក្នុងការផលិតទំនិញដើមកំណើត បានប្តូរតម្រូវការចំណាត់ថ្នាក់បន្ទាត់ពន្ធ។ លក្ខខណ្ឌខាងក្រោមនេះត្រូវបានភ្ជាប់ជាមួយនឹងប្រព្រឹត្តិកម្មនេះ :

- សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់  និង  ឧបករណ៍ និងឯកសារការណែនាំ ឬឯកសារព័ត៌មាន ដែលមានវត្ថុមានជាមួយនឹងទំនិញ មិនមានវិក្កយបត្រដោយឡែកពីទំនិញដើមកំណើត និង
- បរិមាណ និងតម្លៃ សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់  និង ឧបករណ៍ និងការណែនាំ ឬឯកសារ ព័ត៌មានដែលភ្ជាប់ជាមួយនឹងទំនិញ ជាទម្លាប់សម្រាប់ទំនិញនោះ។

ឧទាហរណ៍ ថាតើវិធាននេះប្រតិបត្តិជាក់ស្តែងយ៉ាងដូចម្តេចនោះ អាចទាក់ទងទៅនឹងពាណិជ្ជកម្ម ម៉ាស៊ីនកាត់ស្មៅ។ សន្មតថា សហគ្រាសផលិតម៉ាស៊ីនកាត់ស្មៅ មានមូលដ្ឋានធំនៅក្នុងប្រទេសសិង្ហបុរី ដែលផលិតម៉ាស៊ីនកាត់ស្មៅសម្រាប់វាលស្មៅសួនច្បារ និងវាលកីឡា ហើយមានបំណងចង់នាំចេញ ផលិតផលរបស់ក្រុមហ៊ុនទៅប្រទេសណូវែលហ្សេឡង់។ ម៉ាស៊ីនកាត់ស្មៅចាត់នៅក្នុង HS ៨៤៣៣.១១ ដោយតម្រូវឲ្យបំពេញបានវិធានដោយឡែកសម្រាប់ផលិតផល RVC (40) ឬ CTSH។ ដោយហេតុថា ម៉ាស៊ីនកាត់ស្មៅប្រភេទនេះ ត្រូវប្រើកាំបិតដោយឡែកសម្រាប់ការប្រតិបត្តិផ្សេងៗគ្នា (វាលកីឡា និង វាលវាយកូនគោល) វាជាការធម្មតាសម្រាប់សហគ្រាសដែលត្រូវតែដាក់បញ្ចូលកាំបិតកាត់ផ្សេងៗក្នុង ពេលតម្លើង (ដែលចាត់ជាគ្រឿងបន្លាស់ក្រោម  HS ៨៤៣៣.៩០.៩០) ក៏ដូចជាម៉ាឡេតកាន់ដែលអាច តម្រូវបាន (ដែលចាត់ក្រោម  HS ៨២០៥.១២) សម្រាប់ប្រើក្នុងការប្តូរកាំបិត។ កាំបិត និងម៉ាឡេតអាច មានដើមកំណើតពីចិន និងមិនតម្រូវឲ្យមានការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ដើម្បីចាត់ទុកថាម៉ាស៊ីនកាត់ ស្មៅថាជាទំនិញដើមកំណើត។

សូមចំណាំថា តម្លៃសម្ភារៈ បន្ទាប់បន្សំ គ្រឿងបន្លាស់  និង ឧបករណ៍ មិនបានផាត់ចោលទេ នៅពេល គណនា  RVC និងអាចចាត់ទុកថាមានដើមកំណើត និងមិនមានដើមកំណើត អាស្រ័យទៅលើករណី នោះ ក្នុងការគណនា RVC។

យើងបានបង្ហាញរួចមកហើយ ពីគោលការណ៍វិធានដើមកំណើត   RVC និង  CTC ក្រោម  AANZFTA ដំណើរការដើម្បីបញ្ជាក់ពីការផ្លាស់ប្តូរជុំកំភួន។ លំហាត់ឧទាហរណ៍ មានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធរង ២។

## ផ្នែក ៧

## ខចានដើមកំណើតក្រៅពី CTC និង RVC

ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែកទី២ ខាងលើ ផលិតផលមួយចំនួនតូចតម្រូវឲ្យបំពេញបាននូវការធ្វើតេស្តដើមកំណើតរបស់ទំនិញសម្រាប់គោលបំណង AANZFTA តាមរយៈវិធានដោយឡែកសម្រាប់ផលិតផល។ ក្នុងករណីខ្លះ វិធានទាំងនោះកំណត់បានពីសង្វាក់ផលិតដែលត្រូវតែឆ្លងកាត់ ដើម្បីឲ្យទំនិញនោះចាត់ទុកជាទំនិញដើមកំណើត។ ពេលដែលទំនិញចាត់ចូលក្នុងក្រុមនេះ ពាណិជ្ជករ គួរដឹងដោយខ្លួនឯងនូវវិធានដោយឡែកសម្រាប់ផលិតផល ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ នៃ AANZFTA។

### វិធានប្រតិកម្មគីមី

គីមីមិនមែនសរីរាង្គចាត់នៅក្នុងជំពូក ២៨ គីមីសរីរាង្គចាត់ក្នុងជំពូក ២៩ សារជាតិសម្លាប់ ជ្រលក់ពណ៌ និងផលិតផលដទៃទៀត ចាត់នៅក្នុងជំពូក ៣២ ដែលមិនមានលក្ខណៈពេញលេញទៅនឹងគោលការណ៍ RVC ឬ CTC មានចែងនៅក្នុងឧបសម្ព័ន្ធ ២។ ផលិតផលគីមីអាចចាត់ទុកជាទំនិញដើមកំណើត ប្រសិនបើផលិតផលទាំងនោះផលិតពីប្រតិកម្មគីមី ដែលកើតឡើងនៅក្នុងភាគី។ "ប្រតិកម្មគីមី" គឺជាសង្វាក់ (រួមបញ្ចូលទាំងសង្វាក់ជីវគីមី) ដែលជាលទ្ធផលពីការបំលែងម៉ូលីគុលចាស់ឲ្យទៅជាម៉ូលីគុលមានរូបរាងថ្មី តាមការបំបែកចង្កោមម៉ូលីគុល និងតាមការបង្កើតចង្កោមម៉ូលីគុលថ្មី ឬតាមការរៀបចំម៉ូលីគុលឆ្លាស់គ្នា។ សម្រាប់គោលបំណងកំណត់ដើមកំណើត ខាងក្រោមនេះមិនចាត់ទុកជាប្រតិកម្មគីមីទេ:

ក) រំលាយនៅក្នុងទឹក ឬប្រើសម្រាប់រំលាយដទៃទៀត

ខ) ដកចេញពីការរំលាយ រួមទាំងការដកទឹកចេញ

គ) បន្ថែម ឬដកទឹកចេញដើម្បីធ្វើឲ្យច្បាស់

### ឧទាហរណ៍វិធានពិសេសដទៃទៀត

នៅក្នុងតារាងខាងក្រោម បង្ហាញពីឧទាហរណ៍មួយចំនួន នៃវិធានដោយឡែកដែលបានរកឃើញនៅក្នុងឧបសម្ព័ន្ធ ២ :

### តារាង ២
### ការបង្ហាញពីវិធានដោយឡែកសម្រាប់ផលិតផល ដោយបញ្ជាក់ពីសង្វាក់ផលិត

| ជំពូករង | អនុជំពូករង | ឈ្មោះទំនិញ | វិធានដោយឡែកសម្រាប់ផលិតផល |
|---|---|---|---|
| ១៥០៩ | ១៥០៩.១០ | ប្រេងអូលីវ-សុទ្ធ | RVC(40) ឬ CC មិនមានតម្រូវការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ដោយផ្តល់ថាទំនិញនេះបានផលិតពីការចម្រាញ់ |
| ២៦២០ | ២៦២០.១១ | អាចម៍លោហៈ ផេះ និងសំណល់ ដែលភាគច្រើនជាស័ង្កសី : កាកស័ង្កសីធ្ងន់ | ដើមកំណើតត្រូវបានផ្តល់ចំពោះទំនិញក្នុង Tariff Sub-heading ដែលយកចេញពីផលិតផល ឬបានប្រើប្រាស់នៅក្នុងភាគី |
| ៣៨០៨ | ៣៨០៨.៩២ | ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់សត្វកកេរ... ផ្សេងទៀត : ថ្នាំកម្ចាត់ផ្សិត | RVC ( 40) ឬ CTSH ដោយផ្តល់ថាយ៉ាងតិច ៥០% នៃទម្ងន់សមាសភាពធាតុផ្សំ ឬធាតុផ្សំត្រូវមានដើមកំណើត |
| ៥៤០៧ | ៥៤០៧.១០ | ក្រណាត់សំពត់ផលិតពីសរសៃស្វិតខ្លាំងដែលធ្វើពីនីឡុង ... | CTC ឬការប្តូរពីក្រណាត់ដែលមិនទាន់រៀបចំបន្ត ឬមិនមែនជាផលិតផលចុងក្រោយ ដោយផ្តល់ថា បានជ្រលក់ ឬបោះពុម្ព និងបានឆ្លងកាត់សង្វាក់ផលិត ២ ដំណាក់កាលនៅក្នុងដែនដីភាគីមួយ ឬច្រើន ដើម្បីក្លាយជាផលិតផលសម្រេច |
| ៦១០៤ | ៦១០៤.១៣ | អាវធំឈុតសម្រាប់ស្ត្រី ឬក្មេងស្រី ដែលធ្វើពីអំបោះសំយោគ | RVC ដោយផ្តល់ថាទំនិញតកាត់ ឬចាក់ជារាង និងដេរផ្គុំនៅក្នុងដែនដីភាគីមួយ ឬច្រើន ឬ CTC |
| ៦៣០២ | ៦៣០២.៣១ | កម្រាលពូកៈ ពីអំបោះ | CC ដោយផ្តល់ថា ការផលិតដំបូងពីក្រណាត់ ដែលក្រណាត់ជាក្រណាត់ឆៅ ឬមិនទាន់ជ្រលក់ និងត្រូវផលិតឲ្យចេញជាផលិតផលម្រេចនៅក្នុងដែនដីភាគីមួយ ឬច្រើន |

## ផ្នែក ៨
## ការរំពឹងទុកដទៃទៀតដើម្បីបំពេញតម្រូវការវិធានដើមកំណើត AANZFTA

### ការបញ្ជូនទំនិញដោយត្រង់

ទំនិញដើមកំណើត AANZFTA អាចរក្សាស្ថានភាពដើមកំណើតបាន ប្រសិនបើទំនិញនោះបាន ដឹកជញ្ជូនទៅភាគីនាំចូល :

- ដោយមិនឆ្លងកាត់ប្រទេសដែលមិនមែនភាគី
- បានឆ្លងកាត់ប្រទេសដែលមិនមែនភាគី តែត្រូវបំពេញលក្ខខណ្ឌមួយចំនួន (សូមមើល ខាងក្រោម)

ការដឹកជញ្ជូនទៅភាគីនាំចូល តាមរយៈភាគី AANZFTA ដទៃទៀត មិនប៉ះពាល់ដល់ស្ថានភាពដើមកំណើតនៃទំនិញឡើយ។ ប្រសិនបើទំនិញបាននាំចូលដោយភាគី AANZFTA ហើយនាំចេញទៅវិញ ភាគីនោះអាចប្រើវិញ្ញាបនបត្រ Back to Back តែត្រូវរក្សាស្ថានភាពដើមកំណើត ដោយផ្អែកលើវិញ្ញាបនបត្រដើម (សូមមើលវិញ្ញាបនបត្រ Back to Back នៅក្នុងផ្នែកទី៩) ។

ទំនិញដែលដឹកជញ្ជូនឆ្លងកាត់ប្រទេសមិនមែនភាគី AANZFTA ហើយរក្សាស្ថានភាពដើមកំណើត លុះត្រាតែ :

- ទំនិញមិនបានឆ្លងកាត់ការផលិតបន្ត ឬការកែច្នៃផ្សេងៗទៀតក្រៅពីដែនដីនៃបណ្តាភាគី ដោយគ្រាន់តែលើកចេញ ដាក់ចូល រក្សាទុក ឬការប្រតិបត្តិផ្សេងទៀតចាំបាច់ដើម្បីរក្សាទំនិញឲ្យស្ថិតក្នុងលក្ខខណ្ឌល្អប្រសើរ ដើម្បីដឹកជញ្ជូនបន្តទៅប្រទេសនាំចូល
- ទំនិញមិនបានបានលក់ដូរនៅក្នុងប្រទេសមិនមែនភាគី
- ការឆ្លងកាត់ ដោយសារមូលហេតុភូមិសាស្ត្រ សេដ្ឋកិច្ច និងជំនាញដឹកជញ្ជូន

### ប្រអប់៥ : ការបញ្ជូនទំនិញដោយត្រង់

ពិចារណាករណី ម៉ាស៊ីនដុតសាច់ដែលបានផលិតនៅប្រទេសវៀតណាម និងបានដឹកទៅអូស្ត្រាលីតាមនាវាដឹកកុងតឺន័រ។ ទំនិញត្រូវដឹកឆ្លងកាត់ហុងកុង ពីព្រោះជាមធ្យោបាយដឹកជញ្ជូនថោកជាងគេ។ នៅហុងកុង កុងតឺន័រត្រូវបានលើកចេញពីនាវាមួយ ដើម្បីរក្សាទុក និងលើកដាក់ចូលនាវាមួយទៀត។ ម៉ាស៊ីនដុតសាច់ មិនបានលក់ដូរនៅហុងកុងទេ។ នាវាមួយទៀតបានដឹកកុងតឺន័រនេះទៅម៉ែលប៊ន។ ការប្រតិបត្តិទាំងនោះមិនបានផ្លាស់ប្តូរស្ថានភាពដើមកំណើតម៉ាស៊ីនដុតសាច់ឡើយ។

បរិក្ខារវះកាត់ នាំចេញពីប្រទេសហ្វីលីពីនទៅណូវ៉ែលហ្សេឡង់ជាដុំ និងមិនទាន់បានសម្លាប់មេរោគសម្រាប់ប្រើប្រាស់ជាផលិតផលចុងក្រោយឡើយ វាអាចបាត់បង់ដើមកំណើតប្រសិនបានដឹកឆ្លងកាត់ហុងកុង ដែលជាទីកន្លែងសម្រាប់សម្លាប់មេរោគ និងបរិក្ខារទាំងនោះនឹងត្រូវខ្ចប់ឡើងវិញសម្រាប់លក់ទៅឲ្យអ្នកប្រើប្រាស់។

## វត្ថុធាតុដូច និងវត្ថុធាតុអាចប្តូរគ្នាបាន

បទប្បញ្ញត្តិមួយចំនួននៅក្នុងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី បានបញ្ជាក់ពីវត្ថុធាតុដូច និងវត្ថុធាតុអាចប្តូរគ្នាបាន ដែលប្រើជាធាតុចូលសម្រាប់ការផលិត ហើយជាញយៗយកមកពីប្រទេសដែលមានដើមកំណើតផ្សេងគ្នា ដោយហេតុថាវាជាវត្ថុធាតុពហុមុខងារតភ្ជាប់ជាចង្កោម ហើយមានការពិបាកក្នុងការញែកចេញពីគ្នា។ សម្រាប់គោលបំណងវិធានដើមកំណើត AANZFTA ការកំណត់វត្ថុធាតុដូច និងវត្ថុធាតុអាចប្តូរគ្នាបាន ថាជាវត្ថុធាតុដើមកំណើត ត្រូវធ្វើឡើងដោយសរីរាង្គវិយោគកម្មនៃវត្ថុធាតុនីមួយៗ ឬ ត្រូវធ្វើឡើងដោយការប្រើគោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ នៃការត្រួតពិនិត្យស្តុកដែលមានស្រាប់ ឬពីការអនុវត្តការគ្រប់គ្រងសារពើភណ្ឌរបស់ភាគីនាំចេញ។

វត្ថុធាតុដូច និងវត្ថុធាតុអាចប្តូរគ្នាបាន ដែលមានកំណត់នៅក្នុង AANZFTA គឺជា "វត្ថុធាតុពហុមុខងារដោយសារថាវាមានប្រភេទតែមួយ និងគុណភាពពាណិជ្ជកម្ម បច្ចេកទេស និងរូបរាងចរិតលក្ខណៈដូចគ្នា ដែលមួយណាក៏អាចបញ្ចូលសម្រាប់ផលិតទំនិញចុងក្រោយបាន និងពិបាកញែកឲ្យដាច់ពីគ្នាសម្រាប់គោលបំណងដើមកំណើត ទោះបីតាមវិធីបែបណា ឬការពិនិត្យត្រួសៗផ្នែកខ្លះក៏ដោយ។

## វត្ថុធាតុដោយប្រយោល

នៅក្រោម AANZFTA វត្ថុធាតុដោយប្រយោល ជានិច្ចជាកាលចាត់ទុកថាជាវត្ថុធាតុដើមកំណើត ដោយមិនគិតពីទីកន្លែងដែលផលិតឡើយ។ តម្លៃរបស់វាត្រូវចុះនៅក្នុងរបាយការណ៍គណនេយ្យរបស់អ្នកផលិតទំនិញ។ AANZFTA បានកំណត់វត្ថុធាតុដោយប្រយោលថាជា "ទំនិញដែលប្រើនៅក្នុងការផលិត សាកល្បង ឬត្រួតពិនិត្យទំនិញ ប៉ុន្តែរូបរាងមិនបញ្ចូលទៅក្នុងទំនិញ ឬទំនិញដែលប្រើសម្រាប់ថែទាំអគារ ឬដាក់បញ្ចូលជាមួយគ្រឿងផ្សំនៅក្នុងការផលិតទំនិញ រួមមាន:

- ប្រេងឥន្ធនៈ និងថាមពល
- គ្រឿងប្រដាប់ប្រដារ ពុម្ព និងចាក់ពុម្ព
- គ្រឿងបន្លាស់ និងវត្ថុធាតុដែលបានប្រើក្នុងការរក្សាគ្រឿងបរិក្ខារ និងអគារ
- ប្រេងសម្រាប់ដាក់គ្រឿងយន្ត ខ្លាញ់ ធាតុផ្សំ និងរាល់វត្ថុធាតុដែលបានប្រើប្រាស់ក្នុងផលិតកម្ម ឬបានប្រើប្រាស់ក្នុងការប្រតិបត្តិគ្រឿងបរិក្ខារ ឬអគារ
- ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ ឧបករណ៍សុវត្ថិភាព និងវត្ថុធាតុផ្គត់ផ្គង់ផ្សេងៗ
- ឧបករណ៍ គ្រឿង និងវត្ថុធាតុផ្គត់ផ្គង់ដែលបានប្រើសម្រាប់សាកល្បង ឬត្រួតពិនិត្យទំនិញ
- សារធាតុដាក់បន្ថែមដើម្បីឲ្យឆាប់ប្រតិកម្មគីមី និងទឹកសម្រាប់រំលាយ
- រាល់ទំនិញណាមួយដែលមិនបញ្ចូលឲ្យទៅជាទំនិញ ប៉ុន្តែប្រើក្នុងការផលិតទំនិញដែលមានហេតុផលសមរម្យដើម្បីបង្ហាញថាជាផ្នែកមួយនៃការផលិត"។

## ផ្នែក ៩
## នីតិវិធីប្រគល់នៃការចេញវិញ្ញាបនបត្រ AANZFTA

នីតិវិធីនៅក្រោម AANZFTA គឺអ្នកនាំចេញស្នើសុំវិញ្ញាបនបត្រដើមកំណើត (Certificate of Origin-CO) បញ្ជាក់ជាផ្លូវការលើផលិតផលដែលអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះ ក្នុងគោលបំណងនាំចេញទៅកាន់ទីផ្សារ AANZFTA។ ដំណាក់កាលមួយចំនួនសម្រាប់នីតិវិធីនេះមានពិភាក្សានៅខាងក្រោម និងមានបញ្ជាក់នៅក្នុងគំនូស ៣។

មុនពេលរៀបចំបែបបទសម្រាប់នីតិវិធីសុំចេញវិញ្ញាបនបត្រ អ្នកនាំចេញត្រូវតែដឹងពីគោលការណ៍និងរបៀបលំអិតនៅក្នុងសៀវភៅនេះ ពីព្រោះអ្នកនាំចេញអាចជ្រើសរើសរវាងការធ្វើតេស្ត RVC ឬ CTC និងជ្រើសរើសការធ្វើតេស្តណាដែលងាយស្រួលជាងគេដើម្បីផលិតផលរបស់ខ្លួន។ ផ្អែកលើលក្ខណៈធម្មជាតិរបស់ផលិតផល និងការប្រើប្រាស់វត្ថុធាតុចូលពីក្រៅប្រទេស របាយកាណ៍ដែលរក្សាទុក ចាត់ថាមានសារៈសំខាន់លើការសម្រេចជ្រើសរើសធ្វើតេស្តវិធានដើមកំណើត។

សម្រាប់គោលបំណងវិធានដើមកំណើត អ្នកនាំចេញក៏ត្រូវដឹងផងដែរថានរណាគឺជា " អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ" នៅក្នុងប្រទេសនាំចេញ។ ព័ត៌មានលំអិតពីអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ មានជូនដំណឹងដោយភាគីនីមួយៗ ទៅលេខាធិការដ្ឋានអាស៊ាន។ ប្រសិនបើមានការកែប្រែអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវជូនព័ត៌មានទៅលេខាធិការដ្ឋានអាស៊ានរាល់ការកែប្រែទាំងនោះ។

### នីតិវិធីនៃការចេញវិញ្ញាបនបត្រដើមកំណើត ( Operational Certificate Procedures-OCP): មួយជំហានម្តងៗ

**ជំហានទី១ - ការត្រួតពិនិត្យមុននាំចេញ។** នៅពេលដែលសហគ្រិន/អ្នកនាំចេញសម្រេចជ្រើសយករបបវិធានដើមកំណើតដែលគេចង់ប្រើ គេត្រូវរៀបចំបែបបទទៅអាជ្ញាធរ /ស្ថាប័នចេញវិញ្ញាបនបត្រស្នើសុំឲ្យត្រួតពិនិត្យដើមកំណើតនៃទំនិញសម្រាប់ការនាំចេញ។ លទ្ធផលពីការត្រួតពិនិត្យជាផ្នែកមួយនៃភស្តុតាងគាំទ្រដើមកំណើត ដែលអ្នកនាំចេញនឹងប្រើប្រាស់សម្រាប់បែបបទសុំ CO។ ការត្រួតពិនិត្យមុននាំចេញ អាចមិនអនុវត្តចំពោះទំនិញ ដោយលក្ខណៈធម្មជាតិ ដើមកំណើតងាយស្រួលនឹងកំណត់។

**ជំហានទី ២ - បែបបទ CO។** បន្ទាប់មកអ្នកនាំចេញ ត្រូវរៀបចំបែបបទទៅអាជ្ញាធរ /ស្ថាប័នចេញវិញ្ញាបនបត្រដើម្បីសុំ CO។ បែបបទត្រូវតែភ្ជាប់មកជាមួយនូវឯកសារភ័ស្តុតាងគាំទ្រ ដែលមានបញ្ជាក់ថាទំនិញគ្រប់លក្ខណ:ដើមកំណើត និងបំពេញបានតម្រូវការទិន្នន័យអប្បបរមា។ តម្រូវការទិន្នន័យអប្បបរមារួមមានព័ត៌មានស្តីពីអ្នកនាំចេញ លំអិតពីការដឹកជញ្ជូន ឈ្មោះមុខទំនិញ សេចក្តីប្រកាសរបស់អ្នកនាំចេញ។ តម្រូវការទិន្នន័យអប្បបរមាមានលំអិតនៅក្នុងតារាង ៣។

**ជំហានទី៣ - ការចេញ CO។ AANZFTA** មានបញ្ជាក់ថា CO ត្រូវតែចេញឲ្យបានកៀកបំផុតបើអាចទៅបាន ប៉ុន្តែមិនឲ្យតិចជាង ០៣ ថ្ងៃនៃថ្ងៃការងារចាប់ពីកាលបរិច្ឆេទនាំចេញ។ ប្រសិនបើមូលហេតុត្រឹមត្រូវណាមួយ CO អាចចេញជាប្រតិសកម្ម ប៉ុន្តែមិនយូរជាង ១២ខែ ចាប់ពីកាលបរិច្ឆេទនាំចេញ។ CO ត្រូវតែបំពេញបាននូវរាល់តម្រូវការទិន្នន័យអប្បបរមាដែលមានបញ្ជាក់នៅក្នុង AANZFTA (លំអិតនៅក្នុងតារាង ៤)។ CO មានសុពលភាពរយ:ពេល ១២ខែ និងត្រូវតែប្រគល់ទៅអាជ្ញាធរគយនៅក្នុងប្រទេសនាំចេញក្នុងកំលុងនោះ។

**ជំហានទី ៤ - ផ្ញើ CO ទៅអ្នកនាំចូល។** ទាំងអ្នកនាំចេញ និងអាជ្ញាធរ /ស្ថាប័នចេញវិញ្ញាបនបត្រត្រូវរក្សាច្បាប់ចម្លង CO ប៉ុន្តែ CO ដើមត្រូវបញ្ជូនដោយអ្នកនាំចេញទៅអ្នកនាំចូលដើម្បីប្រគល់ទៅអាជ្ញាធរគយនៅក្នុងប្រទេសនាំចូល។ ទំនិញច្រើនមុខអនុញ្ញាតឲ្យប្រកាសនៅក្នុង CO (តែមួយ) បានដោយផ្តល់ថា ទំនិញនីមួយៗ មានដើមកំណើតទៅតាមសិទ្ធិរបស់វា។

**ជំហានទី ៥ - អ្នកនាំចូលត្រូវផ្តល់ CO ព្រមជាមួយនឹងប្រកាសរបស់អ្នកនាំចេញ។** នៅពេលប្រកាសនាំចូល អ្នកនាំចូលត្រូវប្រគល់ CO ទៅអាជ្ញាធរគយនៃប្រទេសនាំចូល និងស្នើសុំប្រព្រឹត្តិកម្មពន្ធអនុគ្រោះសម្រាប់ទំនិញនៅក្រោម AANZFTA។

### គំនូសតាង ៣

### ដំណាក់កាលនីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រAANZFTA សម្រាប់វិធានដើមកំណើត



### តារាង ៣
### តម្រូវការទិន្នន័យអប្បបរមា- ការដាក់ពាក្យសុំវិញ្ញាបនបត្រដើមកំណើត

តម្រូវការទិន្នន័យអប្បបរមាបែបបទសម្រាប់ចេញវិញ្ញាបនបត្រដើមកំណើតមាន:

| | |
|---|---|
| លំអិតអ្នកនាំចេញ | ឈ្មោះ អាសយដ្ឋាន និងលំអិតពីទំនាក់ទំនងរបស់អ្នកនាំចេញ |
| លំអិតពីការដឹកញ្ជូន (បែបបទដោយឡែកពីគ្នា តម្រូវសម្រាប់ការដឹកជញ្ជូននីមួយៗ) | (i) ឈ្មោះ និងអាសយដ្ឋានអ្នកទទួល<br>(ii) ព័ត៌មានលំអិតគ្រប់គ្រាន់សម្រាប់សម្គាល់ការដឹកជញ្ជូន ដូចជា: លេខបញ្ជាទិញរបស់អ្នកនាំចូល លេខវិក្កយបត្រ និងកាលបរិច្ឆេទ និងប័ណ្ណដឹកតាមយន្តហោះ ឬប័ណ្ណដឹកតាមនាវា ឬប័ណ្ណដឹកជញ្ជូន<br>(iii) កំពង់ផែរើទំនិញ ប្រសិនបើដឹង |
| ឈ្មោះទំនិញ | (i) លំអិតឈ្មោះទំនិញដែលរួមទាំងសុខដុមកូដ (កម្រិត ៦ខ្ទង់) និងប្រសិនបើអាច លេខផលិតផល និងឈ្មោះ យីហោ<br>(ii) ព័ត៌មានផ្សេងៗទាក់ទងទៅនឹងលក្ខខណ្ឌដើមកំណើត |
| ប្រកាសរបស់អ្នកនាំចេញ | ប្រកាសដែលបំពេញដោយអ្នកនាំចេញ ឬតំណាងដែលបានផ្តល់សិទ្ធិចុះហត្ថលេខា និងកាលបរិច្ឆេទ និងសេចក្តីពន្យល់ដែលមានឈ្មោះ និងតួនាទីរបស់អ្នកចុះហត្ថលេខា។ ប្រកាសត្រូវតែរួមមានសេចក្តីថ្លែងការណ៍លំអិតដែលផ្តល់នៅក្នុងបែបបទពិត និងត្រឹមត្រូវ។ |

## តារាង ៤
## តម្រូវការទិន្នន័យអប្បបរមា- វិញ្ញាបនបត្រដើមកំណើត

តម្រូវការទិន្នន័យអប្បបរមាសម្រាប់បញ្ចូលទៅក្នុងវិញ្ញាបនបត្រដើមកំណើតមានៈ

| | |
|---|---|
| លំអិតអ្នកនាំចេញ | ឈ្មោះ អាសយដ្ឋាន និងលំអិតពីទំនាក់ទំនងរបស់អ្នកនាំចេញ |
| លំអិតពីការដឹកញ្ជូន (បែបបទដោយឡែកពីគ្នាតម្រូវសម្រាប់ការដឹកជញ្ជូននីមួយៗ) | (i) ឈ្មោះ និងអាសយដ្ឋានអ្នកទទួល<br>(ii) ព័ត៌មានលំអិតគ្រប់គ្រាន់សម្រាប់សម្គាល់ការដឹកជញ្ជូន ដូចជា លេខបញ្ជាទិញរបស់អ្នកនាំចូល លេខវិក្កយបត្រ និងកាលបរិច្ឆេទ និង ប័ណ្ណដឹកតាមយន្តហោះ ឬប័ណ្ណដឹកតាមនាវា ឬប័ណ្ណដឹកជញ្ជូន<br>(iii) កំពង់ផែរើទំនិញ ប្រសិនបើដឹង |
| ឈ្មោះទំនិញ | (i) លំអិតឈ្មោះទំនិញដែលរួមទាំងសុខដុមកូដ (កម្រិត៦ខ្ទង់) និងប្រសិនបើអាច លេខផលិតផល និងឈ្មោះ យីហោ<br>(ii) ព័ត៌មានផ្សេងៗទាក់ទងទៅនឹងលក្ខខណ្ឌដើមកំណើត<br>(iii) តម្លៃ FOB[1] |
| វិញ្ញាបនបត្រដែលចេញដោយស្ថាប័ន/អាជ្ញាធរចេញវិញ្ញាបនបត្រ | វិញ្ញាបនបត្រដែលចេញដោយស្ថាប័ន/អាជ្ញាធរចេញវិញ្ញាបនបត្រ ដោយផ្អែកលើភ័ស្តុតាងដែលបានផ្តល់ ទំនិញដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រដើមកំណើត ត្រូវបំពេញបាននូវតម្រូវការវិធានដើមកំណើត |
| លេខរៀងវិញ្ញាបនបត្រដើមកំណើត | លេខរៀងដែលដាក់នៅលើវិញ្ញាបនបត្រ ផ្តល់ដោយស្ថាប័ន/អាជ្ញាធរចេញវិញ្ញាបនបត្រ |

[1] នៅក្នុងករណីអូស្ត្រាលី និងណូវែលហ្សេឡង់ វិញ្ញាបនបត្រដើមកំណើត ឬវិញ្ញាបនបត្រ Back to Back ដែលពុំមានបញ្ជាក់តម្លៃ FOB ត្រូវភ្ជាប់មកជាមួយនូវប្រកាសដែលបានធ្វើឡើងដោយអ្នកនាំចេញ បញ្ជាក់តម្លៃ FOB នៃទំនិញនីមួយៗ ដែលមានរៀបរាប់នៅក្នុងវិញ្ញាបនបត្រដើមកំណើត។

### ទម្រង់វិញ្ញាបនបត្រដើមកំណើតAANZFTA

ភាគី AANZFTA បានឯកភាពយកទម្រង់គំរូសម្រាប់វិញ្ញាបនបត្រដើមកំណើត AANZFTA។ តារាងត្រូវបានរៀបចំជាជំនួយបន្ថែម សម្រាប់ការណែនាំដើម្បីបំពេញព័ត៌មានស្តីពីលក្ខខណ្ឌដើមកំណើតនៅក្នុងទម្រង់ CO។ ទម្រង់គំរូ និងការណែនាំ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធរង នៃការណែនាំនេះ។ អ្នកនាំចេញអូស្ត្រាលី និងណូវែលហ្សេឡង់ មានផ្តល់ជម្រើសក្នុងការដាក់បញ្ចូលតម្លៃ FOB ទៅក្នុងប្រអប់ទី៩ នៃទម្រង់ CO ឬផ្តល់ព័ត៌មានដោយឡែកនៅក្នុងប្រកាសអ្នកនាំចេញ ដែលត្រូវតែភ្ជាប់មកជាមួយ CO (សូមមើលឧបសម្ព័ន្ធរង ៨)។

### វិញ្ញាបនបត្រដើមកំណើតBack to Back

ក្នុងករណីខ្លះ អាចចាំបាច់សម្រាប់ការដឹកជញ្ជូនឆ្លងតាមរយៈ " ប្រទេស AANZFTA បន្ទាប់" ទៅភាគីទិសដៅចុងក្រោយ។ ប្រសិនបើទំនិញដើមកំណើត AANZFTA ឆ្លងកាត់ "ភាគី AANZFTA បន្ទាប់" អ្នកនាំចេញនៅក្នុង "ភាគី AANZFTA បន្ទាប់" អាចរៀបបែបបទសុំទៅស្ថាប័ន/អាជ្ញាធរចេញវិញ្ញាបនបត្រនៅក្នុងប្រទេសនោះ ឲ្យចេញវិញ្ញាបនបត្រ Back to Back ដើម្បីធានាថាទំនិញទាំងនោះគ្រប់លក្ខណៈពេញលេញសម្រាប់ទទួលប្រព្រឹត្តិកម្មពន្ធអនុគ្រោះនៅក្នុងប្រទេសទិសដៅចុងក្រោយ។ AANZFTA បានចែងថា ស្ថាប័ន /អាជ្ញាធរចេញវិញ្ញាបនបត្រ ត្រូវចេញ Back to Back CO ដោយបញ្ជាក់ថាលក្ខខណ្ឌខាងក្រោមនេះ ត្រូវបានគោរព :

- សុពលភាពនៃវិញ្ញាបនបត្រដើម ឬច្បាប់ចម្លងបញ្ជាក់
- រយៈពេលនៃសុពលភាពវិញ្ញាបនបត្រ Back to Back មិនលើសពីរយៈពេលនៃសុពលភាពវិញ្ញាបនបត្រដើម
- ទំនិញដែលនាំចេញដោយប្រើ Back to Back CO មិនឆ្លងកាត់សង្វាក់ផលិតបន្ថែមណាមួយនៅក្នុងប្រទេស AANZFTA បន្ទាប់ លើកលែងតែការខ្ចប់ ឬសកម្មភាពដឹកជញ្ជូនណាមួយដូចជា លើកចេញ ដាក់ចូល រក្សាក្នុងឃ្លាំង ឬការប្រតិបត្តិចាំបាច់ណាមួយសម្រាប់រក្សាទំនិញឲ្យស្ថិតនៅក្នុងលក្ខខណ្ឌល្អប្រសើរ ឬសម្រាប់ដឹកជញ្ជូនបន្តទៅកាន់ភាគីនាំចូល AANZFTA និង
- វិញ្ញាបនបត្រ Back to Back ត្រូវមានព័ត៌មានពាក់ព័ន្ធ CO ដើម តាមតម្រូវការទិន្នន័យអប្បបរមា (មើលក្នុងតារាង ៨)។ តម្លៃ FOB គឺជាតម្លៃ FOB នៃទំនិញដែលនាំចេញពីប្រទេសបន្ទាប់នៃភាគី AANZFTA។

គួរចំណាំថា នីតិវិធីពិនិត្យផ្ទៀងផ្ទាត់ ដែលមានចែងនៅក្នុងវិធាន ១៧ និង ១៨ នៃឧបសម្ព័ន្ធវិធានដើមកំណើត AANZFTA ស្តីពីនីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រ ក៏អនុវត្តផងដែរសម្រាប់ Back to Back CO។

## ការផ្ទៀងផ្ទាត់ដើមកំណើតAANZFTA

ពេលខ្លះ អាជ្ញាធរគយនៅក្នុងប្រទេសនាំចូល AANZFTA អាចមានការសង្ស័យពីភាពស្របច្បាប់នៃ CO ឬឯកសារភ័ស្តុតាងគាំទ្រដើមកំណើតទំនិញ។ ក្នុងករណីនេះ កិច្ចព្រមព្រៀងមានផ្តល់នីតិវិធីផ្ទៀងផ្ទាត់បញ្ជាក់ដើមកំណើត - ដែលរួមទាំងការស៊ើបអង្កេតនៅក្នុងប្រទេសដើមកំណើត។ នីតិវិធីពិនិត្យផ្ទៀងផ្ទាត់ មានពិភាក្សានៅក្នុងឧបសម្ព័ន្ធវង ១។

## ការរក្សាទុកឯកសារ

OCP តម្រូវឲ្យអ្នកនាំចេញ អ្នកនាំចូល សហគ្រិន និងអាជ្ញាធរចេញវិញ្ញាបនបត្រ រក្សាទុករាល់ឯកសារពីការនាំចេញ និងនាំចូលចាំបាច់ សម្រាប់បំភ្លឺថាទំនិញពាក់ព័ន្ធ គ្រប់លក្ខណ:ទទួលប្រព្រឹត្តិកម្មអនុគ្រោះ ក្នុងរយ:ពេល ០៣ឆ្នាំ។ របាយការណ៍នេះ អាចរក្សាទុកជាអេឡិចត្រូនិក។

## ការទទួលស្គាល់CO ដោយអាជ្ញាធរនាំចូល

នៅក្នុងស្ថានភាពធម្មតាមួយចំនួន អាជ្ញាធរនាំចូលពុំមានសាកសួរពីភាពស្របច្បាប់នៃ CO សម្រាប់ទំនិញដែលស្ថិតនៅក្នុងវិញ្ញាបនបត្រ ដែលធ្វើឲ្យការនាំចូលទទួលបានផលប្រយោជន៍ពីប្រព្រឹត្តិកម្មអនុគ្រោះ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលមានសកម្មភាពពិនិត្យបញ្ជាក់ដើមកំណើតប្រព្រឹត្តិកម្មអនុគ្រោះអាចពន្យារនៅក្នុងកំលុងស៊ើបអង្កេត។

ប្រសិនបើអ្នកនាំចេញ ផ្លាស់ប្តូរទិសដៅនៃការនាំចេញបន្ទាប់ពីទំនិញនោះបាននាំចេញរួច ប៉ុន្តែមុនពេលបញ្ចេញទំនិញដោយអាជ្ញាធរនាំចូល អ្នកនាំចេញត្រូវសុំ CO ថ្មីសម្រាប់ទំនិញដែលបានផ្លាស់ប្តូរទិសដៅនាំចេញ។ CO ដើមត្រូវតែផ្តល់នៅពេលស្នើសុំ CO ថ្មី។

ប្រសិនបើទំនិញនៅក្នុង CO ត្រូវបានដឹកជញ្ជូនតាមដែនដីនៃប្រទេសមិនមែនភាគី AANZFTA អាជ្ញាធរគយនៃប្រទេសនាំចូល នឹងតម្រូវឲ្យអ្នកនាំចូលផ្តល់ឯកសារដូចខាងក្រោម:

- ប័ណ្ណដឹកជញ្ជូន ដែលបានចេញដោយប្រទេសនាំចេញ
- CO ដែលបានចេញដោយស្ថាប័ន/អាជ្ញាធរចេញវិញ្ញាបនបត្រពាក់ព័ន្ធនៃប្រទេសនាំចេញ
- ច្បាប់ដើមវិក្កយបត្រទំនិញ និង
- ឯកសារគាំទ្រដែលបញ្ជាក់ថា បានបំពេញទៅនឹងតម្រូវការ "ដឹកជញ្ជូនដោយផ្ទាល់"។

**ការបូកផ្សំ និង វិញ្ញាបនបត្រដើមកំណើត**

វិធាន AANZFTA ស្តីពីការបូកផ្សំបានចែងថា ទំនិញដែលផ្តុំពីទំនិញដើមកំណើត AANZFTA ហើយប្រើជាវត្ថុធាតុសម្រាប់ផលិតទំនិញ "ទំនិញបន្ទាប់ ( Intermediate Good)" ត្រូវចាត់ទុកជាទំនិញដើមកំណើតនៅក្នុងភាគី ដែលទំនិញចុងក្រោយនោះបានផលិត។

ប្រសិនបើសហគ្រិន/អ្នកនាំចេញនៃទំនិញចុងក្រោយ មានបំណងទាញយកគុណសម្បត្តិពីបទប្បញ្ញត្តិនេះ ចាំបាច់ណាស់ដែលពួកគេត្រូវមានឯកសារគ្រប់គ្រាន់សម្រាប់បង្ហាញពី "ទំនិញបន្ទាប់" នាំចូលពីប្រទេស AANZFTA ហើយមានដើមកំណើតពី AANZFTA។ ឧទាហរណ៍ថា ប្រសិនបើ "ទំនិញបន្ទាប់" បាននាំចូលក្រោមសន្ធិសញ្ញា AANZFTA នោះ ទំនិញត្រូវតែមាន CO ភ្ជាប់មកជាមួយ ហើយសហគ្រិន/អ្នកនាំចេញនៃទំនិញចុងក្រោយត្រូវរក្សា CO នេះ។

## ផ្នែក ១០

## ការប្រៀបធៀបខចានដើមកំណើត AANZFTA និង FTA ដទៃទៀត

វិធានដើមកំណើត AANZFTA ដែលបានពិភាក្សានៅក្នុងកូនសៀវភៅព័ត៌មាននេះ គឺសម្រាប់សម្រួលការកើនឡើងពាណិជ្ជកម្មនៅក្នុងតំបន់ តាមការផ្តល់ដល់អ្នកនាំចេញនូវកម្រិតពិចារណាទន់ភ្លន់ ក្នុងការសម្រេចជ្រើសរើសរបៀបសម្រាប់ផ្តល់ដើមកំណើតដល់ទំនិញរបស់ពួកគេ។ ភាពទន់ភ្លន់បន្ថែមបានផ្តល់តាមរយៈបទប្បញ្ញត្តិដឺមីនីម៉ីស ដែលភ្ជាប់ជាមួយវិធាន CTC និងជម្រើសវិធីសាស្រ្តគណនាសម្រាប់គោលបំណងគណនា RVC។ ទាំងនោះអាចនិយាយបានថា វិធាន AANZFTA មិនខុសពីវិធានទាំងឡាយដែលកំពុងអនុវត្តនៅក្រោម FTA ដទៃទៀតដែលអាស៊ានបានចរចារួច។

ឧបសម្ព័ន្ធវង ៣ បង្ហាញពីភាពដូច និងខុសគ្នានៃ ROO និង OCP សម្រាប់កិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងអាស៊ានទាំង ៥ ដទៃទៀត : កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ASEAN Trade in Goods Agreement-ATIGA) កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន ( ASEAN-Japan Comprehensive Economic Partnership Agreement-AJCEP) កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-កូរ៉េ (ASEAN-Korea Trade in Goods-AKTIG) កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា (ASEAN-India Trade in Goods-AITIG) កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ចិន (ASEAN-China Trade in Goods-ACTIG)។ ចំណុចចម្បងៗនៃការប្រៀបធៀបមានពិភាក្សាខាងក្រោម។

### ភាពស្រដៀងគ្នានៃគោលការណ៍

FTA បួន (មើលនៅក្នុងឧបសម្ព័ន្ធវង ៣ តារាង ៣.១.ក) ប្រើ (សម្រាប់ផលិតផលច្រើន) វិធានសមភាពដែលអ្នកនាំចេញអាចជ្រើសយកស្តង់ដារវិធានសមាសភាគតម្លៃតំបន់ ៤០ភាគរយ ឬប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិត ៤ខ្ទង់។

FTA ទាំងប្រាំមួយ អនុញ្ញាតឲ្យធ្វើការបូកផ្សំក្នុងចំណោមភាគីនៃកិច្ចព្រមព្រៀងនោះ ដោយផ្តល់ថាធាតុចូលនៃផលិតផលចុងក្រោយនីមួយៗ បានបំពេញទៅនឹងវិធានដើមកំណើត FTA នោះ។

FTA ទាំងអស់ លើកលែងតែ FTA រវាងអាស៊ាន និងជប៉ុន RVC អាចគណនាបានតាមរូបមន្តគណនាដោយផ្ទាល់ (Build-up) ឬប្រយោល (build –down)។

មានផ្នែកជាច្រើននៃ OCP អនុវត្តដូចគ្នានៅក្រោម FTA ទាំងអស់។

ភាពដូចគ្នារវាងកិច្ចព្រមព្រៀងទាំងនោះ មានសារៈសំខាន់ណាស់ ព្រោះអាចជៀសវាងបាននូវការភ័ន្តច្រឡំ ដែលអ្នកនាំចេញនឹងប្រឈមក្នុងការព្យាយាមយល់អំពីរបៀបប្រតិបត្តិផ្សេងៗគ្នា នៃវិធានដើមកំណើត។ ភាពដូចគ្នាខ្លាំងក្លានេះ ធ្វើឲ្យមានភាពងាយស្រួលសម្រាប់អ្នកនាំចេញក្នុងការអនុវត្តជាក់ស្តែង ឧទាហរណ៍តម្រូវការរក្សាឯកសារជាដើម។

## ភាពខុសគ្នានៃគោលការណ៍

វិធានដើមកំណើត ATIGA មានលក្ខណៈជឿនលឿនជាងកិច្ចព្រមព្រៀងដទៃទៀត ក្នុងការសម្រួលការគណនា RVC បូកផ្សំ តាមការអនុញ្ញាតឲ្យមាន Partial Cumulation (តាមមូលដ្ឋានគិតភាគរយ) នៃតម្លៃវត្ថុធាតុដែលមាន RVC តិចបំផុត ២០ភាគរយ។ របៀបគណនា RVC យ៉ាងណានោះ មានបង្ហាញពីការប្រើ Partial Cumulation សម្រាប់គណនា ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ៦ នៃ ATIGA។

ការគណនា RVC រវាងអាស៊ាន និងជប៉ុន FTA មានបញ្ជាក់តែពីវិធីសាស្រ្តគណនា RVC តាមការគណនាដោយប្រយោល។

មានការគិតខុសគ្នាផងដែរ នៅក្នុងកិច្ចព្រមព្រៀងទាំងនោះ ពីវិធានដឺមីនីម៉ីស ទោះបីស្ទើរតែ FTA ទាំងអស់បានអនុញ្ញាត (ចំពោះស្ទើរតែគ្រប់ផលិតផលទាំងអស់) Non-CTC ធាតុចូលគ្រប់លក្ខណៈសម្រាប់ផលិតផលចុងក្រោយរហូតដល់ ១០ភាគរយ នៃតម្លៃ FOB របស់ផលិតផលចុងក្រោយ។ មិនមានបទប្បញ្ញត្តិដឺមីនីម៉ីសនៅក្នុងកិច្ចព្រមព្រៀងឥណ្ឌា និងចិនទេ ព្រោះកិច្ចព្រមព្រៀងទាំងពីរនេះមិនបានអនុញ្ញាតឲ្យមានវិធាន CTC តែមួយ សម្រាប់វិធានដើមកំណើត។

## ឧបសម្ព័ន្ធ ១
## នីតិវិធីផ្ទៀងផ្ទាត់ក្រោមវិធានដើមកំណើត AANZFTA

នីតិវិធីផ្ទៀងផ្ទាត់ក្រោម AANZFTA សម្រាប់វិធានដើមកំណើត មានលំអិតនៅក្នុងវិធាន ១៧ និង ១៨ នៃឧបសម្ព័ន្ធស្តីពីនីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រដើមកំណើត។ នីតិវិធីមានសង្ខេបដូចខាងក្រោម :

### ការផ្តួចផ្តើមនីតិវិធីផ្ទៀងផ្ទាត់

នៅក្នុងករណីទាំងឡាយណាដែលអាជ្ញាធរគយនៃប្រទេសនាំចូល មានការសង្ស័យភាពមិនត្រឹមត្រូវក្នុងការស្នើសុំដើមកំណើតក្រោម AANZFTA កិច្ចព្រមព្រៀងអនុញ្ញាតឲ្យអាជ្ញាធរទាំងនោះ ចាប់ផ្តើមនីតិវិធីផ្ទៀងផ្ទាត់ទៅនឹងករណីទាំងនោះ។ អាជ្ញាធរនឹងធ្វើការពន្យារប្រព្រឹត្តិកម្មអនុគ្រោះពន្ធចំពោះទំនិញដែលបានប៉ះពាល់ នៅក្នុងកំលុងស៊ើបអង្កេត។ នៅពេលចាប់ផ្តើមអង្កេតដើមកំណើតទំនិញ AANZFTA អនុញ្ញាតឲ្យអាជ្ញាធរនាំចូល :

- បង្កើតវិធានការពិនិត្យប្រតិសកម្ម ដើម្បីពិនិត្យសុពលភាពវិញ្ញាបនបត្រដើមកំណើត
- ស្នើសុំព័ត៌មានពីអ្នកនាំចូលពាក់ព័ន្ធ ចំពោះទំនិញដែលប៉ះពាល់ និង
- ស្នើសុំជាលាយលក្ខណ៍អក្សរទៅស្ថាប័ន/អាជ្ញាធរនៅក្នុងប្រទេសនាំចេញ ដើម្បីសួររកព័ត៌មានពីអ្នកនាំចេញ ឬអ្នកផលិតទំនិញ។

អាជ្ញាធរនៅក្នុងប្រទេសនាំចូលអាចរកឃើញថា ករណីនោះមានសារៈសំខាន់ដែលពួកគេត្រូវតែធ្វើការចុះពិនិត្យផ្ទាល់នៅប្រទេសនាំចេញ ដើម្បីផ្ទៀងផ្ទាត់ដើមកំណើតទំនិញលើទំនិញដែលមានបញ្ហា។ នៅក្នុងករណីនេះ អាជ្ញាធរនៃប្រទេសនាំចូល ត្រូវស្នើសុំសម្រាប់ការចុះផ្ទៀងផ្ទាត់ផ្ទាល់យ៉ាងតិច ៣០ថ្ងៃមុនកាលបរិច្ឆេទស្នើ។ ប្រសិនបើអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ នៅក្នុងប្រទេសនាំចេញ ដែលបានចេញ CO មិនមែនភ្នាក់ងាររដ្ឋាភិបាល នោះអាជ្ញាធរនៃប្រទេសនាំចូល ត្រូវជូនដំណឹងទៅអាជ្ញាធរគយនៅក្នុងប្រទេសនាំចេញស្តីពីចំណាប់អារម្មណ៍ ក្នុងការស្វែងយល់ពីការចុះផ្ទៀងផ្ទាត់នេះ។

**ប្រអប់: តម្រូវការព័ត៌មានសម្រាប់ផ្ទៀងផ្ទាត់**

នៅពេលសរសេរពាក្យស្នើសុំសម្រាប់ការចុះផ្ទៀងផ្ទាត់ អាជ្ញាធរនៃប្រទេសនាំចូលត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម (ជាអប្បបរមា)៖

- អត្តសញ្ញាណនៃអាជ្ញាធរគយ ដែលស្នើសុំ
- ឈ្មោះអ្នកនាំចេញ ឬអ្នកផលិតនៃប្រទេសនាំចេញ ដែលទំនិញជាប់ក្នុងការចុះពិនិត្យបញ្ជាក់
- ត្រូវមានកាលបរិច្ឆេទនៃការសរសេរស្នើសុំ
- កាលបរិច្ឆេទ និងទីកន្លែងនៃការចុះផ្ទៀងផ្ទាត់
- គោលបំណង និងទំហំនៃការស្នើសុំចុះផ្ទៀងផ្ទាត់ រួមទាំងឯកសារយោងជាក់លាក់សម្រាប់ទំនិញចុះផ្ទៀងផ្ទាត់ និង
- ឈ្មោះ និងតួនាទីនៃមន្ត្រីអាជ្ញាធរគយ ឬអាជ្ញាធរពាក់ព័ន្ធដទៃទៀតរបស់ប្រទេសនាំចូល ដែលនឹងចូលរួមចុះផ្ទៀងផ្ទាត់។

**ការឆ្លើយតបទៅនឹងការផ្ទៀងផ្ទាត់**

បណ្តាភាគីដែលបានស្នើសុំ ត្រូវផ្តល់ព័ត៌មាន ឆ្លើយតបទៅនឹងការស្នើសុំរបស់ប្រទេសអាជ្ញាធរនាំចូល ក្នុងកំលុង ៩០ថ្ងៃ នៃកាលបរិច្ឆេទដែលបានស្នើសុំ។ នៅក្នុងករណី ដែលអាជ្ញាធរនាំចូលមានគម្រោងចុះផ្ទៀងផ្ទាត់ទៅប្រទេសនាំចេញ អាជ្ញាធរ /ស្ថាប័នចេញវិញ្ញាបនបត្រដែលស្ថិតក្រោមការស៊ើបអង្កេតត្រូវទាក់ទងទៅអ្នកនាំចេញ ឬអ្នកផលិត និងស្នើពួកគេ អនុញ្ញាតឲ្យមានការចុះផ្ទៀងផ្ទាត់ដោយប្រទេសនាំចូល និងផ្តល់រាល់ព័ត៌មានដែលបានស្នើសុំស៊ើបអង្កេតទៅអាជ្ញាធរនាំចូល។

អាជ្ញាធរស៊ើបអង្កេតនៃប្រទេសនាំចូល មិនអាចចុះផ្ទៀងផ្ទាត់នៅក្នុងបរិវេណ ឬរោងចក្ររបស់អ្នកនាំចេញ ឬអ្នកផលិត ដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនឡើយ។ ការមិនយល់ព្រមត្រូវផ្តល់ក្នុងកំលុង ៣០ថ្ងៃ នៃការស្នើសុំចុះផ្ទៀងផ្ទាត់ ឬអាជ្ញាធរ /ស្ថាប័នចេញវិញ្ញាបនបត្រត្រូវតែណែនាំអាជ្ញាធរសុំស៊ើបអង្កេតថា ការស្នើសុំចុះផ្ទៀងផ្ទាត់ត្រូវបានបដិសេធ។ អ្នកនាំចេញ ឬអ្នកផលិតដែលដឹងខ្លួនឯងថាមានការស្នើសុំចុះផ្ទៀងផ្ទាត់ ត្រូវយល់ថាការខកខានក្នុងការឆ្លើយតបជាវិជ្ជមានទៅ

នឹងការស្នើសុំចុះផ្ទៀងផ្ទាត់ ឬការខកខានមិនបានផ្តល់ព័ត៌មានដែលបានស្នើសុំ អាចនាំឲ្យមានការបដិសេធប្រព្រឹត្តិកម្មពន្ធអនុគ្រោះ ចំពោះទំនិញដែលប៉ះពាល់នោះ។

ក្រោម AANZFTA អ្នកនាំចេញ និងអ្នកផលិតត្រូវដឹងថា អាជ្ញាធរស៊ើបអង្កេត និងស្ថាប័នចេញ CO ត្រូវរក្សាជាសម្ងាត់នូវរាល់ព័ត៌មានដែលចាត់ទុកជាសម្ងាត់ និងព័ត៌មានដែលបានប្រមូលនៅពេលចុះផ្ទៀងផ្ទាត់ ។

## លទ្ធផលនៃការផ្ទៀងផ្ទាត់

តាមនីតិវិធីផ្ទៀងផ្ទាត់នៅក្នុងវិធានដើមកំណើត AANZFTA អាជ្ញាធរនៃប្រទេសនាំចូលត្រូវបញ្ចប់ការស៊ើបអង្កេតនៅក្នុងកំលុង ១៥០ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំព័ត៌មានពីស្ថាប័នចេញ CO សម្រាប់ទំនិញជាប់ការអង្កេត។ ការសរសេរជាលាយលក្ខណ៍អក្សរចុងក្រោយរបស់អាជ្ញាធរស៊ើបអង្កេតថា ទំនិញដែលជាប់អង្កេតអាចទទួលប្រព្រឹត្តិកម្មពន្ធអនុគ្រោះ ត្រូវផ្តល់ទៅភាគីពាក់ព័ន្ធទាំងអស់ក្នុងកំលុង ៦០ថ្ងៃ នៃការទទួលព័ត៌មានចាំបាច់សម្រាប់ធ្វើការសម្រេច។ នៅពេលដែលអាជ្ញាធរគយបានបញ្ចប់ថាទំនិញជាប់អង្កេតគ្រប់លក្ខណៈពេញលេញជាទំនិញដើមកំណើត រាល់ប្រព្រឹត្តិកម្មពន្ធអនុគ្រោះដែលបានពន្យារក្នុងកំលុងស៊ើបអង្កេតត្រូវទទួលបានដូចដើមវិញ។

## គំនូសតាង ៤

## កាលវិភាគសម្រាប់ផ្ទៀងផ្ទាត់



## ឧបសម្ព័ន្ធខ ២
## លំហាត់អនុវត្តវិធានដើមកំណើត

លំហាត់អនុវត្តខាងក្រោមមានគោលបំណង ជួយអ្នកនាំចេញឲ្យយល់ដោយខ្លួនឯងពីវិធានដើមកំណើត AANZFTA។

### ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ (CTC)

**លំហាត់ទី១**

វ៉ាល់ (សន្ទះបិទបើក) នាំចូលវៀតណាមពីប្រទេសចិន សម្រាប់កែច្នៃបន្ត និងនាំចេញទៅណូវែលហ្សេឡង់។ ផលិតផលចុងក្រោយចាត់នៅក្នុងបន្ទាត់ពន្ធ ៨៤៨១.១០ និងវ៉ាល់ដំបូងចាត់នៅក្នុងបន្ទាត់ពន្ធ ៨៤៨១.៩០។

វិធានសម្រាប់ទំនិញ ៨៤៨១.១០ គឺ RVC (40) ឬ CTH ឬ RVC (35) + CTSH

តើផលិតផលចុងក្រោយ ជាទំនិញដើមកំណើតដែរឬទេ ដោយប្រើវិធាន CTC?

**លំហាត់ទី២**

អ្នកផលិតបំពង់ទីបស្ពាន់ ( HS ៧៤១១.១០) នៅប្រទេសម៉ាឡេស៊ី ដោយនាំចូលចំនៀរស្ពាន់ ( HS ៧៤០៣.១៣) ពីអូស្ត្រាលី។ ដុំស្ពាន់មានប្រភពដើមពីប្រទេសប៉ាប់ព័រញូវគីនី និងស្ពាន់ដែលមិនទាន់កែច្នៃ (HS ៧៤០២) នាំចូលដោយអូស្ត្រាលីសម្រាប់រំលាយ។

វិធានសម្រាប់ទំនិញ HS ៧៤០៣.១៣ គឺ RVC (40) ឬ CTH
វិធានសម្រាប់ទំនិញ HS ៧៤១១.១០ គឺ RVC (40) ឬ CTH

តើបំពង់ទីបស្ពាន់មានដើមកំណើតដែរឬទេ ដោយប្រើវិធាន CTC?

**លំហាត់ទី៣**

ម៉ាស៊ីនជ្រើសរើស ( HS ៨៤៣៣.៦០) ផលិតនៅប្រទេសអូស្ត្រាលី សម្រាប់នាំចេញទៅឥណ្ឌូនេស៊ី។ ម៉ាស៊ីនផ្សំម៉ូទ័រអេឡិចត្រូនិកដែលមានវត្ថុធាតុមានដើមកំណើត និងមិនមានដើមកំណើត (HS ៨៥០១) ពីជប៉ុន និង កុងតាក់ (HS ៨៥១៩) ពីកូរ៉េ។

វិធានសម្រាប់ទំនិញ HS ៨៤៣៣.៦០ គឺ RVC (40) ឬ CTSH

តើម៉ាស៊ីនជ្រើសរើសមានដើមកំណើតដែរឬទេ ដោយប្រើវិធាន CTC?

**លំហាត់ទី៤**

ម៉ាស៊ីនបញ្ចូលខ្យល់ពោងសុវត្ថិភាព ( HS ៨៧០៨.៩៩) សម្រាប់រថយន្ត ផលិតនៅប្រទេសថៃ។ វត្ថុធាតុដើមនាំចូលពីជប៉ុន ប្រើក្នុងសង្វាក់ផលិតកម្ម។ វត្ថុធាតុដើមទាំងនោះគឺ ប្រដាប់បញ្ឆេះ ( HS ៣៦០៣.០០) ប្រដាប់ច្រោះ ( HS ៧៣១៤.១២) និង ប្រដាប់ខ្នាស់ ( HS ៨៥៣៦.៩០)។ ម៉ាស៊ីនបញ្ចូលខ្យល់ មានបញ្ចូលហ្គាស់កំប៉ុងតូចផលិតនៅឥណ្ឌូនេស៊ី ដែលមានដើមកំណើត AANZFTA និងម៉ាស៊ីនបញ្ចូលខ្យល់ចាត់នៅក្នុង HS ៨៧០៨.៩៩។

វិធានសម្រាប់ទំនិញ HS ៨៧០៨.៩៩ គឺ RVC (40) + CTSH

តើម៉ាស៊ីនបញ្ចូលខ្យល់ពោងសុវត្ថិភាព មានដើមកំណើតដែរឬទេ ដោយប្រើវិធាន CTC?

**លំហាត់ទី៥**

ម៉ាស៊ីនចាប់ដប ( HS ៨៤២២.៣០) ផលិតនៅប្រទេសណូវែលហ្សេឡង់។ វត្ថុធាតុនាំចូលពីប្រទេស អាល្លឺម៉ង់ ប្រើនៅក្នុងសង្វាក់ផលិតម៉ាស៊ីន រួមមានទាំងម៉ាស៊ីនស៊ីឡាំងដែលប្រើដោយទឹក ( HS ៨៤១២.២១) ថ្លឹងទម្ងន់ (HS ៨៤៣១.៣៩) និងសំបកកង់ (HS ៤០១២.៩០)។

វិធានសម្រាប់ទំនិញ HS ៨៤២២.៣០ គឺ RVC (40) ឬ CTSH

តើម៉ាស៊ីនចាប់ដប មានដើមកំណើតដែរឬទេ ដោយប្រើវិធាន CTC?

## សមាសភាគតម្លៃតំបន់ (RVC)

### លំហាត់ ទី៦

កាំបិតសម្រាប់ផ្ទះបាយ (HS ៨២១១.៩១) ផលិតនៅសិង្ហបុរីលក់តម្លៃ $១០។ ដងកាន់ធ្វើពីលោហធាតុ (HS ៨២១១.៩៥) តម្លៃ $៥.៦០ នាំចូលពីជប៉ុន។ ផ្លែកាំបិត ( HS ៨២១១.៩៤) មានតម្លៃ $៣.៧៥ ផលិតនៅប្រទេសឥណ្ឌូនេស៊ី និងមានដើមកំណើត AANZFTA។

វិធានសម្រាប់ទំនិញ HS ៨២១១.៩១ គឺ RVC (40) ឬ CC

តើកាំបិតសម្រាប់ផ្ទះបាយ មានដើមកំណើតដែរឬទេ ដោយប្រើវិធាន RVC?

### លំហាត់ ទី៧

គ្រឿងសង្ហារិមពីឈើ ( HS៩៤០៣.៥០) ផលិតនៅម៉ាឡេស៊ីលក់តម្លៃ $១០០។ ផ្នែករបស់សង្ហារិម (HS៩៤០៣.៩០) នាំចូលពីចិនតៃវ៉ាន់។ ផ្នែកទាំងនេះមានតម្លៃ $៦៣ និង និងវត្ថុធាតុមួយចំនួនទៀត មានដើមកំណើត AANZFTA ផលិតនៅម៉ាឡេស៊ី មានតម្លៃ $៣៥។

វិធានសម្រាប់ទំនិញ HS ៩៤០៣.៥០ គឺ RVC (40) ឬ CTH ឬ RVC (35) + CTSH

តើសង្ហារិម មានដើមកំណើត AANZFTA ដែរឬទេ?

### លំហាត់ទី ៨

ប្រអប់លេខរថយន្ត ( HS៨៧០៨.៤០) ផលិតនៅអូស្ត្រាលីលក់តម្លៃ $១០០០។ ប្រអប់លេខ ផលិតពីវត្ថុធាតុតម្លៃ $៣០០ នាំចូលពីកូរ៉េ (HS ៧៣១៨) វត្ថុធាតុតម្លៃ $២៨០ នាំចូលពីសហរដ្ឋអាមេរិក (HS ៨៧០៨.៩៩) និងបញ្ចូលតម្លៃ $១២៥ វត្ថុធាតុដែលមិនមានដើមកំណើត AANZFTA ពីប្រទេសឥណ្ឌូនេស៊ី ។

វិធានសម្រាប់ទំនិញ HS ៨៧០៨.៤០ គឺ RVC (40)

តើប្រអប់លេខមានដើមកំណើតដែរឬទេ?

**លំហាត់ទី ៩**

គ្រឿងបង្អង់ស្ងួរសម្រាប់រថយន្ត (HS ៨៧០៨.៩២) ផលិតនៅប្រទេសថៃលក់តម្លៃ $១៥០។ វត្ថុធាតុតម្លៃ $៣៣ សម្រាប់ផលិតគ្រឿងបង្អង់ស្ងួរ ផលិតនៅថៃ និងវត្ថុធាតុមិនមានដើមកំណើតតម្លៃ $៨ ទៀត នាំមកពីប្រទេសម៉ាឡេស៊ី។ ពលកម្មសម្រាប់ផលិតគ្រឿងបង្អង់ស្ងួរនីមួយៗ មានតម្លៃ $៩ ប្រាក់វិភាជន៍ $៣ និងថ្លៃដឹកជញ្ជូនដល់កំពង់ផែនាំចេញមានតម្លៃ $៣ ក្នុងមួយគ្រឿង។ សហគ្រិនចំណេញ $៦ ពីការលក់ក្នុងមួយគ្រឿង។

វិធានដើមកំណើតសម្រាប់ទំនិញ HS ៨៧០៨.៩២ គឺ RVC (40)

តើគ្រឿងបង្អង់ស្ងួរមានដើមកំណើតដែរឬទេ?

**លំហាត់ទី ១០**

ម៉ាស៊ីនកំដៅម្ហូប ( HS ៨៥១៦.៥០) ផលិតនៅវៀតណាមលក់តម្លៃ $២០០។ រ៉េស៊ីសស្តង់កំដៅអេឡិចត្រូនិក ( HS ៨៥១៦.៨០) មានតម្លៃ $១០០ និងផ្នែកមួយចំនួនទៀតនៃរ៉េស៊ីសស្តង់ ( HS ៨៥១៦.៩០) មានតម្លៃ $២០ នាំចូលពីហុងកុង។

វិធានសម្រាប់ទំនិញ HS ៨៥១៦.៥០ គឺ RVC (40) ឬ CTH ឬ RVC (35) + CTSH

តើម៉ាស៊ីនកំដៅម្ហូប មានដើមកំណើតដែរឬទេ?

## ចម្លើយនៅនឹងលំហាត់

### លំហាត់ដោយប្រើវិធានដើមកំណើតCTC

**លំហាត់ទី១ :** វិធានដើមកំណើតសម្រាប់ផលិតផលដែលចាត់នៅក្នុង HS ៨៤៨១.១០ តម្រូវថា រាល់វត្ថុមិនមានដើមកំណើតត្រូវតែចាត់នៅក្នុងជំពូករងដទៃទៀតក្រៅពី ៨៤៨១។ ដោយហេតុថា វ៉ាល់ (សន្ទះបិទបើក) នាំចូលចាត់នៅក្នុង HS ៨៤៨១ ទំនិញនេះពុំអាចមានលក្ខណៈពេញលេញជាទំនិញដើមកំណើតឡើយ ដូចនេះវាគឺជាទំនិញមិនមានដើមកំណើតដោយប្រើវិធាន CTC។ គួរកត់សម្គាល់ផងដែរថា ទំនិញនេះ អាចមានដើមកំណើត ប្រសិនបើវាបំពេញបាន RVC ៣៥ ភាគរយ។

**លំហាត់ទី២** : វិធានដើមកំណើតសម្រាប់ផលិតផលដែលចាត់នៅក្នុង HS ៧៤១១ តម្រូវថា រាល់វត្ថុធាតុមិនមានដើមកំណើតត្រូវចាត់នៅក្នុងជំពូករងដទៃទៀត (ជំពូករងណាក៏បានលើកលែងតែ HS ៧៤១១)។ ដោយការនាំចូលចំនៀរស្ពាន់ចាត់នៅក្នុង HS ៧៤០៣ ដូចនេះបំពង់ទីបស្ពាន់បំពេញបានតម្រូវការវិធានដើមកំណើត ដូចនេះវាជាទំនិញដើមកំណើត។ គួរកត់សម្គាល់ផងដែរថា ចំនៀរស្ពាន់ជាក់ស្តែងជាទំនិញដើមកំណើត ដូចនេះវាមិនចាំបាច់បំពេញតម្រូវការវិធានដើមកំណើតទេ ពីព្រោះវាជាទំនិញដើមកំណើតនៅក្នុងដែនដីរបស់ភាគី FTA។ វាជាទំនិញដើមកំណើត ពីព្រោះវិធានដើមកំណើតសម្រាប់ផលិតផលដែលបានចាត់នៅក្នុង HS ៧៤០៣ តម្រូវថា វត្ថុធាតុមិនមានដើមកំណើតត្រូវចាត់នៅក្នុងជំពូករងដទៃទៀត (ជំពូករងដទៃក្រៅពី HS ៧៤០៣)។ ដោយការនាំចូលស្ពាន់មិនទាន់កែច្នៃចាត់នៅក្នុង HS ៧៤០២ ដូចនេះចំនៀរស្ពាន់ បំពេញបានវិធានដើមកំណើត និងវាជាទំនិញមានដើមកំណើត។

**លំហាត់ទី៣** : វិធានដើមកំណើតសម្រាប់ផលិតផលដែលចាត់នៅក្នុង HS ៨៤៣៣.៦០ តម្រូវថា រាល់វត្ថុធាត់មិនមានដើមកំណើត ត្រូវចាត់នៅក្នុង Subheading ដទៃណាមួយ ( Subheading ណាមួយក៏បានលើកលែងតែ HS ៨៤៣៣.៦០)។ ដោយការនាំចូលម៉ូទ័រអេឡិចត្រូនិច និងកុងតាក់ចាត់នៅក្នុង HS ៨៥០១ និង ៨៥១៩ - ទាំងពីរមិនស្ថិតនៅក្នុង HS ៨៤៣៣.៦០ ដូចនេះ ម៉ាស៊ីនជ្រើសរើសបំពេញបានវិធានដើមកំណើត និងជាទំនិញមានដើមកំណើត។

**លំហាត់ទី៤** : តាមវិធាន CTC ម៉ាស៊ីនបញ្ចូលខ្យល់ពោងសុវត្ថិភាព ចាត់ទុកថាជាទំនិញមានដើមកំណើត ពីព្រោះពុំមានវត្ថុធាតុដែលមិនមានដើមកំណើតចាត់នៅក្នុង HS ៨៧០៨.៩៩ឡើយ និងហ្វាស់កំប៉ុងតូចពីឥណ្ឌូនេស៊ី ជាទំនិញមានដើមកំណើតនៅក្រោមវិធានបូកផ្សំ របស់ AANZFTA។ ដោយវិធានដោយឡែកសម្រាប់ផលិតផលនៅក្នុងករណីនេះ តម្រូវឲ្យបំពេញបានទាំងវិធាន CTC និង RVC (៤០) យើងមិនអាចកំណត់ថាម៉ាស៊ីនបញ្ចូលខ្យល់ពោងសុវត្ថិភាពជាទំនិញដើមកំណើត ដោយពុំដឹងពីលទ្ធផលនៃការគណនាវិធាន RVC ឡើយ។

**លំហាត់ទី៥** : វិធានដើមកំណើតសម្រាប់ផលិតផលដែលចាត់នៅក្នុង HS ៨៤២២.៣០ តម្រូវថា វត្ថុធាតុមិនមានដើមកំណើតទាំងអស់ ត្រូវចាត់នៅក្នុង Subheading ដទៃ ( Subheading ណាមួយក៏បានលើកលែងតែ HS ៨៤២២.៣០)។ ដោយការនាំចូលម៉ាស៊ីនស៊ីឡាំងដែលប្រើដោយទឹក ម៉ាស៊ីនថ្លឹងទម្ងន់ និងសំបកកង់ ចាត់នៅក្នុងអនុជំពូកក្រៅពី HS ៨៤២២.៣០ នោះម៉ាស៊ីនចាប់ដបបំពេញបានតម្រូវការវិធានដើមកំណើត និងជាទំនិញដើមកំណើតក្រោមវិធាន CTC ។

### លំហាត់ដោយប្រើវិធានRVC

**លំហាត់ទី៦ :** ដោយប្រើរូមមន្តគណនាដោយប្រយោល ( Build-down) យើងចាប់ផ្តើមពី FOB តម្លៃ ($១០) និងដកចេញវត្ថុធាតុមិនមានដើមកំណើតពីជប៉ុន ( $៥.៦០) ហើយចែកជាមួយតម្លៃ FOB នោះ យើងនឹងឃើញលទ្ធផល ៤៤ ភាគរយ។ ដូចនេះកាំបិតជាទំនិញដើមកំណើត។ គួរកត់សម្គាល់ផងដែរ ថាតម្លៃផ្លែកាំបិតដែលផលិតនៅឥណ្ឌូនេស៊ី ប្រើវិធានបូកផ្សំជាមួយនឹងតម្លៃដែលផលិតនៅសឹង្ហបុរី។

$$RVC = \frac{១០ - ៥.៦០}{១០} = \frac{៤.៤០}{១០} = ០.៤៤ * ១០០\% = ៤៤ \text{ ភាគរយ}$$

**លំហាត់ទី៧ :** គ្រឿងសង្ហារិមស្ថិតនៅក្នុងចម្ងល់ថាមិនបានបំពេញទៅនឹងវិធាន RVC (40) ដោយហេតុថា ការប្រើរូបមន្តដោយប្រយោលបង្ហាញថា វត្ថុធាតុនាំចូលពីតៃវ៉ាន់មានតម្លៃ ៦០ ភាគរយ មិនមានដើមកំណើត។ គ្រឿងសង្ហារិមក៏មិនអាចបំពេញបានតម្រូវការវិធាន CTC ពីព្រោះថាទាំងគ្រឿងសង្ហារិម និងផ្នែករបស់វាចាត់នៅក្នុង HS ៩៤០៣។ ប៉ុន្តែគ្រឿងសង្ហារិមអាចបំពេញបានវិធានដើមកំណើតទី៣ គឺ RVC (35) + CTSH ដោយហេតុថា ការគណនាតាមរូបមន្តប្រយោលបង្ហាញថា គ្រឿងសង្ហារិមមាន RVC ៣៧ ភាគរយ និងវិធាន CTSH បានបំពេញទៅនឹងតម្រូវការនៃផ្នែករបស់សង្ហារិមដែលនាំចូលក្រោម HS ៩៤០៣.៩០ ហើយសង្ហារិមដែលជាផលិតផលចុងក្រោយចាត់នៅក្នុង HS ៩៤០៣.៥០។

**លំហាត់ទី៨ :** ការគណនា RVC តាមវិធីសាស្ត្រគណនាដោយប្រយោល ដើម្បីដកចេញវត្ថុធាតុ $៣០០ នាំចូលពីកូរ៉េ $២៨០ នាំចូលពីអាមេរិក និង $១២៥ ដែលមិនមានដើមកំណើតនាំចូលពីឥណ្ឌូនេស៊ី ពីតម្លៃ FOB $១.០០០។ ការគណនាបានបញ្ជាក់ថា ប្រអប់លេខមិនមានដើមកំណើត ពីព្រោះវាមាន RVC ៣០ ភាគរយ ដែលមិនអាចបំពេញបាន RVC ៤០ភាគរយ។

$$RVC = \frac{១០០០ - ៣០០ - ២៨០ - ១២៥}{១០០០} = \frac{២៩៥}{១០០០} = ០.៣០ * ១០០\% = ៣០ \text{ ភាគរយ}$$

**លំហាត់ទី៩ :** ដើម្បីឲ្យឃើញថា គ្រឿងបង្អង់ស្វរសម្រាប់រថយន្តមានដើមកំណើត យើងត្រូវគណនា RVC ដោយប្រើរូបមន្តដោយផ្ទាល់។ ទាំងវត្ថុធាតុរបស់ប្រទេសម៉ាឡេស៊ី និង ថៃ ចាត់ទុកថាជាវត្ថុធាតុ AANZFTA ដោយប្រើវិធានបូកផ្សំ។

$$RVC = \frac{៥១.០០ + ៩.០០ + ៣.០០ + ៦.០០ + ៣.០០}{១៥០} = \frac{៦២}{១៥០} = ០.៥១៣$$

ការគណនាបង្ហាញថា ជាមួយ RVC ៥១.៣ ភាគរយ គ្រឿងបង្អង់ស្វរបំពេញបានទៅនឹងកម្រិត RVC ៥០ភាគរយ ក្រោមវិធាន AANZFTA។

**លំហាត់ទី១០ :** ប្រើរូបមន្តគណនាដោយប្រយោលបង្ហាញថា មានតែ ៣៦ ភាគរយនៃតម្លៃម៉ាស៊ីនកំដៅម្ហូបជា RVC ដូចនេះវាមិនអាចបំពេញបានវិធាន RVC (40) ទេ។ វិធាន CTH ក៏មិនអាចបំពេញបានដែរ ដោយហេតុថារ៉េស៊ីសស្តង់ និងផ្នែកមួយចំនួនទៀតរបស់វាស្ថិតនៅក្នុងជំពូករង (HS ៨៥១៦) តែមួយជាមួយម៉ាស៊ីនកំដៅម្ហូប។ ប៉ុន្តែដោយរ៉េស៊ីសស្តង់ (HS ៨៥១៦.៨០) និងផ្នែកដទៃទៀត (HS ៨៥១៦.៩០) បានប្តូរទៅ Subheading (HS ៨៥១៦.៥០) នោះម៉ាស៊ីនកំដៅម្ហូបអាចបំពេញបានវិធាន RVC (35) + CTSH។

## ឧបសម្ព័ន្ធ ៣
## ការប្រៀបធៀបគោលការណ៍ទទានដើមកំណើត និង កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានជ្រើសយក

តារាងខាងក្រោមបញ្ជាក់ពីចំណុចដូច និងខុសគ្នារវាងកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងប្រាំមួយរបស់អាស៊ាន :

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី និងណូវ៉ែលហ្សេឡង់ បានចុះហត្ថលេខា នាថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន បានចុះហត្ថលេខា នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩
- ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន-ជប៉ុន បានចុះហត្ថលេខា នាថ្ងៃ ទី១៤ ខែមេសា ឆ្នាំ២០០៨
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-កូរ៉េ បានចុះហត្ថលេខា នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា បានចុះហត្ថលេខា នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ចិន បានចុះហត្ថលេខា នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤

## ឧបសម្ព័ន្ធខ ៤
## ទម្រង់គំរូសម្រាប់វិញ្ញាបនបត្រដើមកំណើត AANZFTA

ឧបសម្ព័ន្ធរងនេះ បង្កើតឡើងវិញ :

(ក) ទម្រង់គំរូដែលបានឯកភាពសម្រាប់វិញ្ញាបនបត្រដើមកំណើត AANZFTA

(ខ) ការណែនាំសម្រាប់បំពេញព័ត៌មាន ស្តីពីដើមកំណើតនៅលើទម្រង់ CO របស់ AANZFTA និង

(គ) ប្រកាសរបស់អ្នកនាំចេញស្តីពីតម្លៃ FOB ដែលអ្នកនាំចេញអូស្ត្រាលី និងណូវែលហ្សេឡង់ ត្រូវតែប្រើ ប្រសិនបើមិនផ្តល់ព័ត៌មានពីតម្លៃ FOB នៅក្នុងប្រអប់ទី៩ នៃ CO។

ច្បាប់ដើម

១. ទំនិញដឹកជញ្ជូនពី (ឈ្មោះ អាសយដ្ឋាន និងប្រទេស របស់អ្នកនាំចេញ)

២. ទំនិញដឹកជញ្ជូនទៅ (អ្នកនាំចូល អាសយដ្ឋាន និងប្រទេស )

លេខវិញ្ញាបនបត្រ                                        ទម្រង់AANZ

**កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី**
**អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA)**
**វិញ្ញាបនបត្រដើមកំណើត**

(បញ្ចូលគ្នាសេចក្តីប្រកាស និង វិញ្ញាបនបត្រ)
បានចេញនៅ............................
(ប្រទេស)
(សូមមើលកំណត់សម្គាល់)

៣. មធ្យោបាយ និងផ្លូវដឹកជញ្ជូន (ប្រសិនបើដឹង)
កាលបរិច្ឆេទផ្ទុកទំនិញ :
ឈ្មោះនាវា/យន្តហោះ :
កំពង់ផែបញ្ចេញទំនិញ :

៤. សម្រាប់សមត្ថកិច្ច

□ ប្រព្រឹត្តិកម្មអនុគ្រោះបានផ្តល់ក្រោម AANZFTA

□ ប្រព្រឹត្តិកម្មអនុគ្រោះមិនបានផ្តល់ក្រោម
(សូមផ្តល់មូលហេតុ)

..........................................................................................

ហត្ថលេខា នៃហត្ថលេខីដែលមានសិទ្ធិនៅប្រទេសនាំចូល

| ៥. លេខរៀងទំនិញ | ៦. ម៉ាក និង លេខកញ្ចប់ទំនិញ | ៧. លេខ និងប្រភេទកញ្ចប់ : ឈ្មោះទំនិញ រួមទាំង HS (៦ខ្ទង់) និងឈ្មោះម៉ាក (ប្រសិនបើមាន) | ៨. លក្ខខណ្ឌដើមកំណើត (សូមមើលកំណត់សម្គាល់) | ៩. បរិមាណ (ទម្ងន់ និង រង្វាស់ផ្សេងៗ) និងតម្លៃ FOB (សូមមើលកំណត់សម្គាល់) | ១០. លេខវិក្កយបត្រ និង កាលបរិច្ឆេទវិក្កយបត្រ |
|---|---|---|---|---|---|
| | | | | | |

១១. សេចក្តីប្រកាសដោយអ្នកនាំចេញ
ការចុះហត្ថលេខាខាងក្រោមនេះបញ្ជាក់ថា ព័ត៌មានលំអិតខាងលើ និងសេចក្តីប្រកាស ពិតជាត្រឹមត្រូវ ថាទំនិញទាំងអស់បានផលិតនៅ :

..........................................................................................
(ប្រទេស)

និងបានបំពេញនូវវិធានដើមកំណើត ដែលមានចែងក្នុងជំពូក ៣ នៃកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ សម្រាប់នាំចេញទៅ :

..........................................................................................
(ប្រទេសនាំចូល)

..........................................................................................
ទីកន្លែង កាលបរិច្ឆេទ ឈ្មោះ ហត្ថលេខានៃហត្ថលេខីដែលមានសិទ្ធិ

១២. ដើម្បីជាមូលដ្ឋានសម្រាប់ការពិនិត្យ បានបញ្ជាក់ថាព័ត៌មាននៅទីនេះគឺត្រឹមត្រូវ និងទំនិញដែលបានរៀបរាប់បំពេញបានទៅនឹងតម្រូវការដើមកំណើតបញ្ជាក់នៅក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

..........................................................................................
ទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា និងត្រា ស្ថាប័ន/អាជ្ញាធរផ្តល់សិទ្ធិចេញវិញ្ញាបនបត្រ

១៣. □ វិញ្ញាបនបត្រ Back to Back □ ប្រើវិក្កយបត្រភាគីទី ៣ □ ចេញប្រតិសកម្ម
□ ដឹមីនីមីស □ បូកផ្សំតំបន់

## កំណត់សម្គាល់វិញ្ញាបនបត្រដើមកំណើត

១. ប្រទេសដែលទទួលស្គាល់ទម្រង់នេះសម្រាប់គោលបំណងប្រព្រឹត្តិកម្មអនុគ្រោះក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន -អូស្ត្រាលី-ណូវែលហ្សេឡង់ (កិច្ចព្រមព្រៀង) :

| | | | | | |
|---|---|---|---|---|---|
| អូស្ត្រាលី | ប្រ៊ុយណេដារូសាឡឹម | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី |
| មីយ៉ាន់ម៉ា | ណូវែលហ្សេឡង់ | ហ្វីលីពីន | សឹង្ហបុរី | ថៃ | វៀតណាម |

(ដែលនីមួយៗ ជាភាគី)

២. **លក្ខខណ្ឌ** : ដើម្បីទទួលបាន ប្រព្រឹត្តិកម្មអនុគ្រោះនៅក្រោម AANZFTA ទំនិញត្រូវតែ :

(ក) ស្ថិតនៅក្រោមឈ្មោះទំនិញដែលអាចទទួលបានសម្បទាននៅក្នុងប្រទេសនាំចូល

(ខ) បំពេញបានរាល់បទប្បញ្ញត្តិពាក់ព័ន្ធជំពូក៣ (វិធានដើមកំណើត) នៃកិច្ចព្រមព្រៀង។

៣. **អ្នកនាំចេញ និង អ្នកទទួល**: លំអិតស្តីពីអ្នកនាំចេញទំនិញ (រួមមានទាំង ឈ្មោះ អាសយដ្ឋាន និងប្រទេស) និងអ្នកទទួល (ឈ្មោះ និងអាសយដ្ឋាន) ត្រូវតែផ្តល់នៅក្នុងប្រអប់ទី ១ និង ទី ២។

៤. **ឈ្មោះទំនិញ** : បរិយាយមុខទំនិញនីមួយៗ នៅក្នុងប្រអប់ទី៧ ត្រូវតែដាក់បរិយាយមុខទំនិញសុខដុម និងប្រព័ន្ធកូដ ( HS) sub-heading កម្រិត ៦ខ្ទង់ ចំពោះទំនិញដែលនាំចេញ និងប្រសិនបើមាន ឈ្មោះទំនិញ និងឈ្មោះម៉ាក។ ព័តមានត្រូវតែលំអិតគ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការកំណត់ដោយមន្ត្រីគយ។

៥. **លក្ខខណ្ឌដើមកំណើត** : សម្រាប់ទំនិញដែលបំពេញបានលក្ខខណ្ឌដើមកំណើត អ្នកនាំចេញត្រូវបញ្ជាក់នៅក្នុងប្រអប់ទី៨ នៃទម្រង់នេះ លក្ខខណ្ឌដើមកំណើត ដែលបង្ហាញនៅខាងក្នុងតារាង:

| **ស្ថានភាពផលិតផល ឬសហគ្រាសនៅក្នុងប្រទេសដែលបានផ្តល់ឈ្មោះនៅក្នុងប្រអប់ទី១១ នៃទម្រង់នេះ** | **ដាក់នៅក្នុងប្រអប់ទី៨** |
|---|---|
| ទំនិញផលិត ឬកកើតទាំងស្រុង តាមមាត្រា ២.១ (ក) នៃកិច្ចព្រមព្រៀង | WO |
| ទំនិញផលិតទាំងស្រុង តាមមាត្រា ២.១ (គ) នៃកិច្ចព្រមព្រៀង | PE |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹងមាត្រា ៤.១(ក) នៃកិច្ចព្រមព្រៀង | RVC |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹងមាត្រា ៤.១(ខ) នៃកិច្ចព្រមព្រៀង | CTH |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹងមាត្រា ៤.២ ប្រសិនបើទំនិញមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ២ និងតម្រូវការដាក់លាក់ទាំងអស់សម្រាប់ផលិតផល ត្រូវបំពេញបាន | |
| ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ | |
| សមាសភាគតម្លៃតំបន់ | |
| ដទៃទៀត រួមទាំងតម្រូវការសង្វាក់ផលិតកម្មជាក់លាក់ ឬសង្វាក់ប្រតិបត្តិ ឬ CTC ឬ RVC និងការរួមបញ្ចូលជាមួយតម្រូវការបន្ថែមដទៃទៀត | PSR (CTC)<br>PSR (RVC)<br>PSR (ដទៃទៀត) |

៦. ទំនិញនីមួយៗ ដែលស្នើសុំប្រព្រឹត្តិកម្មពន្ធអនុគ្រោះ ត្រូវតែគ្រប់លក្ខណ:ទៅតាមសិទ្ធិរបស់វា : គួរកត់សម្គាល់ថា រាល់ទំនិញត្រូវតែបំពេញបានដោយឡែកពីគ្នា ពីសិទ្ធិរបស់វា។ ទាំងនេះពាក់ព័ន្ធនៅពេលដែលទំនិញដូច តែមានទំហំ និងផ្នែកខុសគ្នា នៅពេលនាំចេញ។

៧. តម្លៃ FOB :

- អ្នកនាំចេញពីរដ្ឋសមាជិកអាស៊ាន ត្រូវផ្តល់តម្លៃ FOB របស់ទំនិញនៅក្នុងប្រអប់ទី៩
- អ្នកនាំចេញពីអូស្ត្រាលី និងណូវែលហ្សេឡង់ អាចបំពេញនៅក្នុងប្រអប់៩ ឬផ្តល់ដាច់ពីគ្នា "ប្រកាសអ្នកនាំចេញ" ដោយបញ្ជាក់ពីតម្លៃ FOB នៃទំនិញ។

៨. វិក្កយបត្រ : បញ្ជាក់ពីលេខវិក្កយបត្រ និងកាលបរិច្ឆេទរបស់ទំនិញនីមួយៗ។ វិក្កយបត្រត្រូវចេញតែម្តងនៅពេលនាំចូលទំនិញទៅភាគីនាំចូល។

៩. វិក្កយបត្រចេញដោយភាគីទីបី : នៅពេលដែលវិក្កយបត្របានចេញដោយប្រទេសទីបីណាមួយ តាមវិធាន ២២ ស្តីពីនីតិវិធីប្រតិបត្តិចេញវិញ្ញាបនបត្រ ប្រអប់ "កម្មវត្ថុសម្រាប់វិក្កយបត្រចេញដោយភាគីទីបី" នៅក្នុងប្រអប់ទី១៣ ត្រូវតែដាក់សញ្ញា (✓)។

១០. វិញ្ញាបនបត្រដើមកំណើត Back to Back : នៅក្នុងករណីចេញវិញ្ញាបនបត្រដើមកំណើត Back to Back អនុលោមតាមកថាខណ្ឌ ៣ វិធាន ១០ ស្តីពីនីតិវិធីប្រតិបត្តិចេញវិញ្ញាបនបត្រ វិញ្ញាបនបត្រដើមកំណើត Back to Back នៅក្នុងប្រអប់ទី១៣ ត្រូវតែដាក់សញ្ញា (✓)។

១១. បញ្ជាក់ចម្លងតាមច្បាប់ដើម : ក្នុងករណីបញ្ជាក់ចម្លងតាមច្បាប់ដើម ពាក្យ "បញ្ជាក់ចម្លងតាមច្បាប់ដើម" ត្រូវសរសេរ ឬបោះត្រានៅក្នុងប្រអប់ទី ១២ និងកាលបរិច្ឆេទនៃការចេញច្បាប់ចម្លង អនុលោមតាមវិធាន ១១ នៃនីតិវិធីប្រតិបត្តិចេញវិញ្ញាបនបត្រ។

១២. សម្រាប់សមត្ថកិច្ច : អាជ្ញាធរគយនៃភាគីនាំចូលត្រូវបញ្ជាក់ (✓) ក្នុងប្រអប់ពាក់ព័ន្ធ ប្រអប់ទី៤ ពីការផ្តល់ និងមិនផ្តល់ប្រព្រឹត្តិកម្មពន្ធអនុគ្រោះ។

១៣. ប្រអប់ ១៣ : ចំណុចនីមួយៗ នៅក្នុងប្រអប់ទី១៣ ត្រូវតែដាក់សញ្ញា ( ✓) តាមទីកន្លែងដែលសមរម្យ ក្នុងករណីដែលពាក់ព័ន្ធទៅនឹងទំនិញលើវិញ្ញាបនបត្រ។

## ការណែនាំការបំពេញព័ត៌មានស្តីពីលក្ខណៈវិនិច្ឆ័យនៃការផ្តល់ដើមកំណើតលើ វិញ្ញាបនបត្រដើមកំណើត AANZFTA

តារាងខាងក្រោម គឺជាការណែនាំសម្រាប់អ្នកអនុវត្តកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ (AANZFTA) ក្នុងការបំពេញប្រអប់ទី៨ នៃទម្រង់វិញ្ញាបនបត្រ AANZFTA។ ឯកសារនេះប្រើជាការណែនាំសម្រាប់អ្នកអនុវត្ត និងមិនភ្ជាប់ជាមួយវិញ្ញាបនបត្រទម្រង់ AANZFTA ឬតម្រូវឲ្យផ្តល់ទៅអាជ្ញាធរនាំចូលឡើយ។

| ស្ថានភាពផលិតផល ឬសហគ្រាសនៅក្នុងប្រទេស ដែលបានផ្តល់ឈ្មោះនៅក្នុងប្រអប់ទី១១ នៃទម្រង់នេះ: | ដាក់នៅក្នុងប្រអប់ទី៨ |
|---|---|
| ទំនិញផលិត ឬកកើតទាំងស្រុង ដោយបាន បំពេញមាត្រា ២.១ (ក) នៃកិច្ចព្រមព្រៀង | WO<br>យល់ដឹងថា "WO" ត្រូវដាក់នៅក្នុងប្រអប់ទី ៨ ប្រសិនបើទំនិញផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ។ |
| ទំនិញផលិតទាំងស្រុង ដោយបានបំពេញមាត្រា ២.១ (គ) នៃកិច្ចព្រមព្រៀង | PE<br>យល់ដឹងថា "PE" ត្រូវដាក់នៅក្នុងប្រអប់ទី ៨ ប្រសិនបើ ទំនិញផលិតទាំងស្រុងនៅក្នុងភាគីមួយ ដោយប្រើវត្ថុធាតុដើមកំណើតទាំងស្រុងពីភាគីមួយ ឬច្រើន។ |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹង មាត្រា៤.១(ក) នៃកិច្ចព្រមព្រៀង | RVC<br>យល់ដឹងថា "RVC" ត្រូវដាក់នៅក្នុងប្រអប់ទី ៨ ប្រសិនបើទំនិញបំពេញបានទៅនឹងតម្រូវការ មាត្រា ៤.១ (ក) សមាសភាគតម្លៃតំបន់ មិនតិចជាង ៤០ ភាគរយ នៃតម្លៃ FOB។ |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹងមាត្រា ៤.១(ខ) នៃកិច្ចព្រមព្រៀង | CTH<br>យល់ដឹងថា "CTH" ត្រូវដាក់នៅក្នុងប្រអប់ទី ៨ ប្រសិនបើទំនិញបំពេញបានទៅនឹងតម្រូវការ មាត្រា ៤.១ (ខ) ដែលវត្ថុធាតុមិនមានដើមកំណើត |

| | |
|---|---|
| | ទាំងអស់ប្រើនៅក្នុងការផលិតទំនិញបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធកម្រិត ៤ ខ្ទង់ (ការផ្លាស់ប្តូរជំពូករង) នៃ HS Code នៅក្នុងភាគី។ |
| មិនផលិត ឬកកើតទាំងស្រុងនៅក្នុងភាគីមួយ ដោយផ្តល់ថាទំនិញបានបំពេញទៅនឹងមាត្រា ៤.២ ប្រសិនបើទំនិញមានបញ្ជាក់នៅក្នុង ឧបសម្ព័ន្ធ ២ និងរាល់តម្រូវការជាក់លាក់ សម្រាប់ផលិតផលត្រូវតែបំពេញ | |
| ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ | PSR (CTC)<br>យល់ដឹងថា "PSR (CTC)" ត្រូវដាក់នៅក្នុង ប្រអប់ទី ៨ ប្រសិនបើលក្ខខណ្ឌដើមកំណើតនៅក្នុងឧបសម្ព័ន្ធ ២ ជាការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ទោះបីជាកម្រិតជំពូក ("CC") កម្រិតជំពូករង ("CTH") កម្រិត Subheading ("CTSH")។ មិនចាំបាច់ដាក់បន្ទាត់ពន្ធដែលប្តូរជាក់ស្តែងឡើយ។ |
| សមាសភាគតម្លៃតំបន់ | PSR (RVC)<br>យល់ដឹងថា "PSR (RVC)" ត្រូវដាក់នៅក្នុង ប្រអប់ទី ៨ ប្រសិនបើលក្ខខណ្ឌដើមកំណើតនៅក្នុងឧបសម្ព័ន្ធ ២ ជា RVC ។ |
| ដទៃទៀត រួមទាំងតម្រូវការសង្វាក់ផលិតកម្មជាក់លាក់ ឬសង្វាក់ប្រតិបត្តិ ឬ CTC ឬ RVC និងការបញ្ចូលជាមួយតម្រូវបន្ថែមដទៃទៀត | PSR (ដទៃទៀត)<br>យល់ដឹងថា "PSR (ដទៃទៀត)" ត្រូវដាក់នៅក្នុង ប្រអប់ទី ៨ ប្រសិនបើលក្ខខណ្ឌដើមកំណើតនៅក្នុងឧបសម្ព័ន្ធ ២ ជាវិធានសង្វាក់ផលិតកម្មជាក់លាក់ ឬសង្វាក់ប្រតិបត្តិ ឬ CTC ឬ RVC និងការបញ្ចូលជាមួយតម្រូវការបន្ថែមដទៃទៀត។ ខាងក្រោមជាឧទាហរណ៍ខ្លះៗ :<br>(i) RVC (40) + CTSH<br>(ii) មិនមានការតម្រូវឲ្យប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ដោយផ្តល់ថា ទំនិញ |

| | |
|---|---|
| | បានចម្អិន នៅក្នុងដែនដីរបស់បណ្តាភាគី<br>(iii) មិនមានការតម្រូវឲ្យប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ដោយផ្តល់ថា ទំនិញបានមកពីការចម្រាញ់<br>(iv) CTSH លើកលែងតែមកពី ២៥២៣.២៩ រហូតដល់ ២៥២៣.៩០<br>(v) ដើមកំណើតត្រូវបានផ្តល់ចំពោះទំនិញដែលនៅក្នុង Subheading នេះបានមកពីផលិតផល ឬការប្រើប្រាស់នៅក្នុងភាគីមួយ<br>(vi) ប្រសិនបើទំនិញបានពីលទ្ធផលនៃ "ប្រតិកម្មគីមី"។ |

**ទម្រង់ប្រកាសរបស់អ្នកនាំចេញ**

"ខ្ញុំ..............................................................................................(ឈ្មោះតំណាងអ្នកនាំចេញ) នៃ
..........................................................................................................(ឈ្មោះក្រុមហ៊ុននាំចេញ)
ប្រកាសថា តម្លៃ FOB នៃទំនិញដែលដាក់នៅក្នុងវិញ្ញាបនបត្រដើមកំណើតលេខ ....................
(បញ្ចូលលេខ CO) នាំចេញពី [អូស្ត្រាលី/ណូវែលហ្សេឡង់] ទៅ...........................................
(ឈ្មោះប្រទេសនាំចូល) គឺដូចខាងក្រោម។

**សម្គាល់** : តម្លៃ FOB ត្រូវដាក់ដោយឡែកសម្រាប់ទំនិញនីមួយៗ ដែលមាននៅក្នុងវិញ្ញាបនបត្រដើមកំណើត។

| **លេខរៀងវិញ្ញាបនបត្រ** | **តម្លៃ FOB** | **ឈ្មោះមុខទំនិញដែលមាននៅក្នុងវិញ្ញាបនបត្រដើមកំណើត** |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

(បន្ថែមបន្ទាត់ ប្រសិនបើចាំបាច់)

......................................................................
(ហត្ថលេខាតំណាងអ្នកនាំចេញ)

......................................................................
(ឈ្មោះតំណាងអ្នកនាំចេញ)

......................................................................
(ឈ្មោះអ្នកនាំចេញ)

......................................................................
(កាលបរិច្ឆេទ)

**Notes on Accompanying CD**

This CD-ROM contains the following:

Part A: Text and schedules of the Agreement Establishing the ASEAN-Australia-New Zealand Free Trade Area (AANZFTA). It also includes the text of the Understanding on Article 1 (Reduction and Elimination of Customs Duties) of Chapter 2 (Trade in Goods Chapter) of the AANZFTA and the Implementing Arrangement for ASEAN-Australia-New Zealand Free Trade Area Economic Co-operation Work Programme Pursuant to Chapter 12 (Economic Cooperation) of the AANZFTA.

Part B: Product Specific Rules (PSR), Certificate of Origin (CO) Form, Exporter's Declaration Form, and Guidelines for Completing the CO Form of the AANZFTA ROO. For tariff reduction schedules for Trade in Goods, please refer to Part A above. Note that tariff reduction schedules as annexed are in HS 2002. Readers/users are advised to refer to the www.asean.org at entry into force of AANZFTA for the HS 2007 version of the tariff reduction schedules.

Utmost care has been done in the preparation/compilation of the files in the CD, should there be any discrepancies, the original legal text, including the schedules of the AANZFTA signed by the Parties shall prevail.



This translation was certified
by Ministry of Economy and Finance of Cambodia